សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# តួនាទីក្រឡាបញ្ជីនៅក្នុងរឿងក្តីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ស្រី យូសេខ**

កញ្ញា **សោម ចាន់ចរិយា**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# មាតិកា

ទំព័រ


សេចក្ដីផ្ដើម------------------------------------------------------------------ ១

## ជំពូកទី១
## សញ្ញាណទូទៅក្រឡាបញ្ជី

ផ្នែកទី១ ក្រឡាបញ្ជីជានរណា ------------------------------------------------ ៤

កថាខណ្ឌទី១ និយមន័យក្រឡាបញ្ជី ------------------------------------------ ៤

កថាខណ្ឌទី២ ដើមកំណើតនៃការកើតក្រឡាបញ្ជី ------------------------------ ៥

កថាខណ្ឌទី៣ គោលបំណងនៃការបង្កើតក្រឡាបញ្ជី ---------------------------- ៥

កថាខណ្ឌទី៤ រចនាសម្ព័ន្ធសាលាដំបូងរាជធានី/ខេត្ត ---------------------------- ៦

## ជំពូកទី២
## ដំណាក់កាលមុនជំនុំជម្រះ

ផ្នែកទី១ នៅដំណាក់កាលអយ្យការ------------------------------------------- ៨

កថាខណ្ឌទី១ តួនាទីក្រឡាបញ្ជីពេលស៊ើបអង្កេតរបស់អង្គអយ្យការ ------------------ ៨

១.១.តួនាទីទទួលសំណុំរឿង ----------------------------------------------- ៨

១.២.តួនាទីទទួលវត្ថុតាង ------------------------------------------------- ៩

១.៣.តួនាទីព្រាងដីកាផ្សេងៗ ---------------------------------------------- ១០

កថាខណ្ឌទី២.តួនាទីក្រឡាបញ្ជីក្រោយពេលស៊ើបអង្កេតអយ្យការ-------------------- ១៣

២.១.ករណីមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា ---------------------------------- ១៣

២.២.ករណីចោទប្រកាន់របស់ព្រះរាជអាជ្ញា------------------------------------ ១៤

ផ្នែកទី២ នៅដំណាក់កាលចៅក្រមស៊ើបសួរ------------------------------------ ១៦

កថាខណ្ឌទី១ តួនាទីក្រឡាបញ្ជីមុនពេលស៊ើបសួរ------------------------------- ១៦

១.១.គោលការណ៍រក្សាការសំងាត់នៃការស៊ើបសួរ------------------------------- ១៦

១.២.ចុះលេខសំណុំរឿងនៅក្នុងសៀវភៅនានា ---------------------------------- ១៧

១.៣.ការតាក់តែងដីកាផ្សេងៗ---------------------------------------------- ១៨

កថាខណ្ឌទី២ តួនាទីក្រឡាបញ្ជីក្នុងដំណើរការនៃនីតិវិធីស៊ើបសួរ-------------------- ១៩

២.១.របៀបការហៅ និងការជូនដំណឹង ---------------------------------------- ១៩

២.២.អំពីការកោះហៅមេធាវី ---------------------------------------------- ១៩

២.៣.ចុះកន្លែងកើតហេតុ ------------------------------------------------- ២០

២.៤.ដឹកនាំសម្បថសាក្សី ---------- ២១

២.៥.ភារកិច្ចរបស់ក្រឡាបញ្ជីបំពេញកិច្ចស៊ើបសួរ ---------- ២២

កថាខណ្ឌទី៣ ភារកិច្ចក្រឡាបញ្ជីក្នុងកិច្ចបិទការស៊ើបសួរ ---------- ២៦

៣.១.ករណីជនត្រូវចោទនៅក្រៅឃុំ ---------- ២៦

៣.២.ករណីជនត្រូវចោទនៅក្នុងឃុំ ---------- ២៧

៣.៣.តួនាទីក្នុងការគ្រប់គ្រងថែរក្សាសំណុំរឿងក្រោយការស៊ើបសួរ ---------- ២៧

៣.៤.តួនាទីក្នុងការទទួលបណ្ដឹងឧទ្ធរណ៍(ប្ដឹងទៅសភាស៊ើបសួរ) ---------- ២៧

## ជំពូកទី ៣

## ដំណាក់កាលជំនុំជម្រះ

ផ្នែកទី១ តួនាទីក្រឡាបញ្ជីមុនពេលសវនាការ ---------- ២៨

កថាខណ្ឌទី១ តួនាទីតាក់តែងលិខិតផ្សេងៗ ---------- ២៩

១.១.ពិនិត្យការបរិច្ឆេទនៃជំនុំជម្រះ ---------- ២៩

១.២.តាក់តែងរូបមន្តដីកាចាត់តំណាងអយ្យការ ---------- ២៩

១.៣.រៀបសំណុំរឿងមុនជំនុំជម្រះ ---------- ៣០

១.៤.កោះហៅភាគីពាក់ព័ន្ធ ---------- ៣០

១.៥.រៀបចំបន្ទប់សវនាការ ---------- ៣០

ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងពេលសវនាការ ---------- ៣១

កថាខណ្ឌទី១ ប្រកាសបើកសវនាការ ---------- ៣១

កថាខណ្ឌទី២ ទម្រង់នៃកំណត់ហេតុសវនាការ ---------- ៣២

កថាខណ្ឌទី៣ ការថយទៅពិភាក្សា ---------- ៣៣

កថាខណ្ឌទី៤ សុពលភាពនៃកំណត់ហេតុជំនុំជម្រះ ---------- ៣៤

ផ្នែកទី៣ តួនាទីក្រឡាបញ្ជីក្នុងការប្រកាសសាលក្រម ---------- ៣៥

កថាខណ្ឌទី១ កិច្ចការក្រឡាបញ្ជីក្នុងពេលប្រកាសសាលក្រម ---------- ៣៥

កថាខណ្ឌទី២ ធ្វើលិខិតជូនដំណឹងសាលក្រមកំបាំងមុខ ---------- ៣៦

សេចក្ដីសន្និដ្ឋាន ---------- ៣៨

អនុសាសន៍

ឧបសម្ព័ន្ធ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ស្រ៊ី យូសេង** និង នាងខ្ញុំឈ្មោះ **សោម ចាន់ចរិយា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី០៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥-២០១៩ បានសរសេរសារណា ដើម្បីបញ្ចប់ការសិក្សា ដែលបានជ្រើសរើសយកប្រធានបទ "**តួនាទីក្រុមប្រឹក្សាក្នុងរឿងក្ដីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត**"

## សូមលំអោនកាយនឹងវាចារចិត្តគោរពដឹងគុណដ៏ធំធេងចំពោះមាតាបិតា

លោកទាំងពីរបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅមើលថែរក្សា ទាំងទឹកក្ដៅ ទឹកត្រជាក់ ថែមទាំងជំរុញលើកទឹកចិត្តកូនគ្រប់ពេលវេលាមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងផ្ដល់នៅសម្ភារៈផ្សេងៗជាពិសេសនោះ គឺផ្ដល់ជាថវិកាផ្គត់ផ្គង់ក្នុងការរៀនសូត្រ តាំងពីថ្នាក់មតេយ្យរហូតដល់ថ្នាក់ឧត្ដមសិក្សា ។ បើគ្មានលោកទាំងពីរ យើងក៏គ្មានអ្វីៗដូចសព្វថ្ងៃនេះដែរ ដូច្នេះកូនមានតែពាក្យអរគុណ និងគោរពដឹងគុណកតញ្ញូតធម៌លោកទាំងទ្វេររហូតតទៅ ។

យើងខ្ញុំ សូមសម្ដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្ដម លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និង បុគ្គលិក នៃសាកលវិទ្យាល័យទាំងអស់ផងដែរ ដែលបានចែករំលែកបទពិសោធន៍ ក៏ដូចជាការផ្ទេរចំណេះដឹង និងតម្រែតម្រង់ទិសដល់យើងកន្លងមក ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ហោ សុភ័ណ្ឌ** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃខិតខំប្រឹងប្រែងណែនាំ កែសម្រួលទាំងអត្ថន័យ ពិនិត្យពាក្យពេចន៍អក្ខរាវិរុទ្ធ ឃ្លោងឃ្លា នៅក្នុងសារណាមួយនេះ ។

យើងខ្ញុំទាំងពីររូបសូមប្រសិទ្ធិពរជ័យជូនដល់លោកដែលមានគុណទាំងអស់ដូចដែលបានធ្វើការរៀបរាប់ខាងលើ សូមអោយលោកបានជួបតែសេចក្ដីសុខ និងពុទ្ធពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈពល កុំបីឃ្លាឃ្លាតឡើយ ។

សូមថ្លែងអំណរគុណដល់មិត្តភក្ដិដែលសិក្សារួមជំនាន់ ព្រមទាំងសិស្សច្បងដែលបានផ្ដល់ជាកម្លាំងចិត្តដល់យើងខ្ញុំក្នុងការសរសេរសារណាមួយនេះឡើង ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានពិគ្រោះយោបល់គ្នានិងសម្រេចចិត្តទៅតាមការចំណង់ចំណូលចិត្ត និងការចាប់អារម្មណ៍របស់យើងទាំងពីរ ដែលបានជ្រើសរើសយកប្រធានបទស្តីពី " **តួនាទីក្រឡាបញ្ជីក្នុងរឿងក្តីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត**"។

ក្រោយពីយើងសិក្សាអស់រយៈពេលច្រើនឆ្នាំកន្លងមកនេះ ក្នុងចំណោមអំណាចទាំងបី យើងខ្ញុំបានចាប់អារម្មណ៍ទៅលើអំណាច តុលាការ បូករួមទាំងការស្រលាញ់ចូលចិត្តផងនោះ យើងបានសង្កេតឃើញថា ក្រឡាបញ្ជីក៏បានចូលរួមចំណែក ជួយបម្រើការក្នុងវិស័យយុត្តិធម៌ផងដែរ ដូច្នេះក្រឡាបញ្ជីក៏មានសារៈសំខាន់ណាស់ក្នុងវិស័យមួយនេះ ។ បើនិយាយជាសាមញ្ញ ក្រឡាបញ្ជីជាដៃស្តាំរបស់ចៅក្រមដែលមានតួនាទីក្នុងការកត់ត្រាយកចំណុចសំខាន់ និងធ្វើការងារទាំងអស់ដែលចៅក្រមប្រគល់ឱ្យ។ មូលហេតុដែលអោយយើងមានបំណងចង់ស្រាវជ្រាវប្រធានបទនេះ គឺយើងសង្កេតឃើញថា រាល់ពេលដែលមានការប្រឡងប្រជែងក្រឡាបញ្ជីម្តងៗ គណៈកម្មាធិការតែងតែចោទជាសំនួរសួរពីតួនាទីរបស់ក្រឡាបញ្ជី ។ ម៉្យាងវិញទៀត គឺប្រធានបទនេះមិនទាន់មានឯកសារ និងអ្នកស្រាវជ្រាវច្រើននៅឡើយ យើងខ្ញុំនឹងខិតខំស្រាវជ្រាវដើម្បីធ្វើជាឯកសារ សម្រាប់ធ្វើជាមូលដ្ឋានសម្រាប់សិស្សនិស្សិតដែលសិក្សាជំនាន់ក្រោយៗ ស្វែងយល់ ។ ទោះបីច្បាប់ស្តីពីលក្ខន្តិកក្រឡាបញ្ជីមិនទាន់ចូលជាធរមានក្តី ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានមាត្រាមួយចំនួនមានការពាក់ព័ន្ធផងដែរ ។ ប៉ុន្តែកំហុស និងចន្លោះខ្វះខាតនៅតែមាន បើមានកំហុសត្រង់ណាក្តី ក្នុងការប្រើប្រាស់ពាក្យពេចន៍ យើងខ្ញុំរង់ចាំទទួលការរិះគុណ និងការកែលំអរក្នុងន័យស្ថាបនាពីសំណាក់ លោកបណ្ឌិត លោកសាស្ត្រាចារ្យ លោកនិងលោកស្រី ព្រមទាំងមិត្តនិស្សិតជានិច្ច ដូចមានពាក្យស្លោកមួយលើកឡើងថា "ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច រាល់កំហុសពាក្យពេចន៍តែងមានអ្នកកែតម្រូវ" ។

# សេចក្តីផ្តើម

ការវិវត្តន៍របស់សង្គមពីមួយថ្ងៃទៅមួយថ្ងៃ តែងតែមានការរីកចំរើនទៅមុខជានិរន្តរ៍។ បើយើងក្រឡេកទៅមើលប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង កាលពីសម័យបុរាណកាលមកនោះការគ្រប់គ្រងសង្គមមនុស្សឱ្យមានសណ្តាប់ធ្នាប់ គឺការដាក់ទោស ឬទណ្ឌកម្មផ្សេងៗ។ គេតែងតែអនុវត្តទៅតាមទំនៀមទំលាប់ប្រពៃណីបុរាណ និងជំនឿសាសនារបស់សង្គម។ កាលណាមានជម្លោះកើតឡើង គេតែងតែទៅប្តឹងព្រះមហាក្សត្រដើម្បីដោះស្រាយឱ្យពួកគេ។ ព្រះមហាក្សត្រសម័យនោះហាក់បីដូចជា ចៅក្រម ដូចសព្វថ្ងៃ ឬ អាចនិយាយបានម្យ៉ាងទៀតថា ជាអាជ្ញាកណ្តាល។ អំណាចវិនិយច្ឆ័យទោសបិតនៅលើព្រះមហាក្សត្រ ដែលព្រះអង្គជាអ្នកកាន់កាប់អំណាចគ្រប់វិស័យទាំងអស់។ ដូច្នេះរាល់ទំនាស់ទាំងឡាយមិនថា រឿងប្រាក់ ឬអ្វីនោះទេ គឺតែងតែត្រូវបានដោះស្រាយដោយព្រះរាជា។ ចំណែកឯ ការដាក់ទោសទាន់វិញ បើទោសស្រាល គឺពិន័យជាមាស ឬប្រាក់ ចំណែកឯទោសធ្ងន់ គឺពិន័យដូចជា យកទៅកប់ក្នុងរណ្តៅ កាត់ម្រាមដៃ ម្រាមជើង ឬច្រមុះជាដើម។[១]

ដូច្នេះស្ថាប័នតុលាការនាសម័យនោះពុំទាន់មានទេទើបតែមានពេលប្រទេសបារាំងមកដាក់អាណានិគមកលើប្រទេសខ្មែរ។ យើងសង្កេតឃើញថា នៅសម័យអាណានិគមនិយមបារាំង លេចចេញនូវការរៀបចំរចនាសម្ព័ន្ធអង្គការតុលាការមួយ គឺបែងចែកដាច់ពីគ្នា ដោយតុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក និងតុលាការសហាតុភាពបារាំង។ ដោយតុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក ជាការវិនិច្ឆ័យក្នុងករណីវិវាទកើតឡើងរវាងជនជាតិខ្មែរ និងជនជាតិខ្មែរដូចគ្នា។ ចំណែកឯតុលាការសហាតុភាពបារាំងជាតុលាការវិនិច្ឆ័យសេចក្តីចំពោះវិវាទដែលបង្កដោយជនជាតិបារាំង។ ក្រោយមកគឺប្រទេសកម្ពុជាយើងទទួលឯករាជ្យពេញលេញ។ ទើបរៀបចំប្រទេសខ្លួនឡើងវិញហើយបានធ្វើវិសោធនកម្មជាបន្តបន្ទាប់នូវរដ្ឋធម្មនុញ្ញារហូតមកដល់សព្វថ្ងៃនេះ សង្គមកម្ពុជាកំពុងតែកែទម្រង់ជាច្រើនជាពិសេស វិស័យ សង្គម។ អ្វីដែលគួរកត់សំគាល់នោះ គឺជាការកែទម្រង់ប្រព័ន្ធតុលាការដែលជាប្រធានមួយកំពុងតែមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីមហាជន ព្រោះអំណាចតុលាការជាអំណាចឯករាជ្យ ហើយថែមទាំងជាអ្នករក្សាអានាគិត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចទាំងនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ថ្នាក់។[២] មានន័យថា ស្ថាប័នតុលាការជាអ្នកទទួលបន្ទុកកាត់សេចក្តីផ្តល់ភាពយុត្តិធម៌។តួអង្គសំខាន់ៗរបស់តុលាការមាន ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី អាជ្ញាសាលា ។ល។ អ្នកទាំងនេះសុទ្ធតែមាន

[២] មាត្រា ១២៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

មុខងាររៀងៗខ្លួននៅក្នុងតុលាការ។ ដោយចៅក្រមជាអ្នកទទួលបន្ទុកជំនុំជម្រះរឿងក្តី។ ចំណែកឯព្រះរាជអាជ្ញាវិញគាត់ជាអ្នកធ្វើបណ្តឹងអាជ្ញាចំពោះអំពើទាំងឡាយណា ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ទូទៅ[៣]។ ចំពោះក្រឡាបញ្ជីវិញគាត់មានមុខងារជាអ្នកជំនួយការក្នុងនីតិវិធីតុលាការ។ វិជ្ជាជីវៈក្រឡាបញ្ជី គឺជាវិជ្ជាជីវៈនៃយុត្តាធិការ ស្ថិតនៅក្នុងលក្ខន្តិកៈដោយឡែកដែលបម្រើឱ្យសេវាយុត្តិធម៌។ វិជ្ជាជីវៈក្រឡាបញ្ជីត្រូវអនុវត្ត តាមក្រមសីលធម៌វិជ្ជាជីវៈ និងធានាផ្តល់សេវាយុត្តិធម៌ដោយសមភាព តម្លាភាព និងឆាប់រហ័ស។[៤]

យ៉ាងណាមិញយើងសង្កេតឃើញថា ក្រសួងយុត្តិធម៌កំពុងតែរៀបចំដាក់បញ្ចូលនូវច្បាប់បួនដែលសុទ្ធតែជាច្បាប់ពាក់ព័ន្ធទៅនឹងការកែទម្រង់ប្រព័ន្ធតុលាការ គឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលច្បាប់ទាំងបីនេះ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥។តែអ្វីដែលជាបញ្ហាចោទសម្រាប់អ្នកអនុវត្តសព្វថ្ងៃនោះ គឺច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី នៅតែជាសេចក្តីព្រាងច្បាប់នៅឡើយ មិនអាចយកមកអនុវត្តបានឡើយ។

បើយើងប្រៀបធៀបទៅនឹងសត្វដំរីមួយដែលកំពុងអុសឈើហ៊ុបមួយយ៉ាងធំ តែដំរីនោះកំពុងតែដំបៅដ៏ធំលើជើងម្ខាងដែលអាចទៅមុខបានយ៉ាងលំបាក។ដូចគ្នាដែរ បើចង់កែទម្រង់ប្រព័ន្ធតុលាការឱ្យមានភាពរលូន លុះត្រាតែច្បាប់ទាំងបួនដែលចែងពីតួនាទីតួអង្គសំខាន់ៗរបស់ប្រព័ន្ធតុលាការ បានចូលជាធរមាន អាចយកមកអនុវត្តទន្ទឹមគ្នា ទើបការកែទម្រង់វិស័យយុត្តិធម៌មានប្រសិទ្ធិភាពឆាប់រហ័ស។

តាមរយៈការប្រកួតប្រជែងប្រឡងចូលរៀនសាលាភូមិន្ទក្រឡាបញ្ជីប៉ុន្មានឆ្នាំចុងក្រោយនេះ គឺសាលាតម្រូវឱ្យបេក្ខជន ប្រឡងវិញ្ញាសារសរសេរ និងវិញ្ញាសារផ្ទាល់មាត់។ ចំពោះវិញ្ញាសារសរសេរតម្រូវឱ្យបេក្ខជនចេះច្បាប់ទូទៅ (ច្បាប់សារធាតុនៃក្រមព្រហ្មទណ្ឌ និងច្បាប់សារធាតុនៃក្រមរដ្ឋប្បវេណី) ចំពោះវិញ្ញាសារផ្ទាល់មាត់វិញអាច ជាសួរសំណួរទូទៅខ្លះ និងនីតិវិធីផ្សេងរបស់ក្រឡាបញ្ជីជាដើម។ ដូច្នេះហើយទើបមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់មិត្តៗនិស្សិតរបស់យើង និងអ្នកស្រាវជ្រាវដ៏ទៃទៀត ប៉ុន្តែដោយសារតែកង្វះខាតជាច្រើននូវវិធានច្បាប់ជាក់ស្តែង និង

[៣] មាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៤] ឯកសារចងក្រង វិជ្ជាជីវៈក្រឡាបញ្ជី រៀបចំដោយៈលោកមួន សៀងលី ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុ (អតីតសិស្សក្រឡាបញ្ជីជំនាន់ទី៣)

ឯកសារផ្សេងៗ នោះជាឧបសគ្គមួយសម្រាប់អ្នកស្រាវជ្រាវ ដូច្នេះទើបជម្រុញឱ្យក្រុមយើងខ្ញុំមានបំណងធ្វើឯកសារស្រាវជ្រាវអំពី"**តួនាទីក្រឡាបញ្ជីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត**" ដើម្បីសិក្សាយល់កាន់តែច្បាស់ តើក្រឡាបញ្ជីនៃសាលាដំបូងរាជធានី/ខេត្តនីមួយៗមានតួនាទីអ្វីខ្លះ? ហើយការអនុវត្តន៍បែបណាប្រសិនបើច្បាប់លក្ខន្តិកៈក្រឡាបញ្ជីមិនទាន់ចូលជាធរមាននូវឡើយ?

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងមានគោលបំណងចម្បងដើម្បីសិក្សាស្រាវជ្រាវពីការងារ ក្រឡាបញ្ជីរបស់អយ្យការ និងការងារក្រឡាបញ្ជីរបស់ចៅក្រម ដែលមានតួនាទីផ្សេងៗពីគ្នាក្នុងការបំរើ ការងារយុត្តិធម៌ ហើយយើងខ្ញុំបានដកស្រង់ចេញពីច្បាប់គោលធំៗ គឺក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការជាមូលដ្ឋាន។ បន្ថែមលើសនេះទៅទៀតនោះ យើងបានដកស្រង់ចេញពីអត្ថបទច្បាប់ អត្ថបទមេរៀននានារបស់សាស្ត្រាចារ្យបង្ហាត់បង្រៀននៅសាលាភូមិន្ទវិជ្ជាជីវៈក្រឡាបញ្ជី សេចក្ដីសម្រេចរបស់តុលាការ ការសាកសួរពីសាស្ត្រាចារ្យណែនាំ សាកសួរពីក្រឡាបញ្ជីផ្សេងៗ និងសិស្សច្បាងដែលទើបបញ្ចប់ការសិក្សាវិជ្ជាជីវៈក្រឡាបញ្ជីជំនាន់៥ ។

ដូច្នេះនៅក្នុងការដំណើរការរឿងក្ដីព្រហ្មទណ្ឌគេបែងចែកជា ៤ដំណាក់កាលធំៗ គឺដំណាក់កាល នៅមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ ដូចពាក្យស្លោកចិនរឿងសោមកុកនិយាយថា "ជូនដំណើរដល់ណាក៏គ្មានទីបញ្ចប់ដែល ព្រោះអ្នកដែលត្រូវទៅគង់តែទៅ" ដោយសារពេលវេលាការស្រាវជ្រាវមានកំណត់កាលកំណត់ ដូច្នេះយើងខ្ញុំសុំលើកយកតែតួនាទីក្រឡាបញ្ជី នៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ។ ដូច្នេះយើងខ្ញុំសុំលើកយកតែចំណុចធំៗ។

**ជំពូកទី១ សញ្ញាណទូទៅក្រឡាបញ្ជី**

**ជំពូកទី២ ដំណាក់កាលមុនជំនុំជម្រះ**

**ជំពូកទី៣ ដំណាក់កាលជំនុំជម្រះ**

# ជំពូកទី១ សញ្ញាណទូទៅក្រឡាបញ្ជី

## ផ្នែកទី១ ក្រឡាបញ្ជីជានរណា

ជាទូទៅប្រជាជនភាគច្រើនប្រាកដជា ស្គាល់ពីស្ថាប័នតុលាការតែអ្នកខ្លះស្គាល់តែចៅក្រម ព្រះរាជអជ្ញា មេធាវី តែប៉ុណ្ណោះព្រោះអ្នកទាំងនេះ គឺជាអ្នករកយុត្តិធម៌ និងការពារយុត្តិធម៌ ប៉ុន្តែពួកគាត់ប្រហែលជាភ្លេចតួអង្គសំខាន់មួយទៀតហើយ ដែលជាអ្នកសកម្មនឹងការងារយុត្តិធម៌ ហើយក៏ជាមនុស្សទីមួយដែលភាគីនៃរឿងក្តីត្រូវជួបនោះគឺ"**ក្រឡាបញ្ជី**"។ ក្រឡាបញ្ជីក៏មានតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការប្រើវិស័យយុត្តិធម៌ដែលជាអ្នកធានានូវខាងបច្ចេកទេសនៃនីតិវិធី និងជាជំនួយការចៅក្រម ព្រះរាជអាជ្ញាក្នុងយុត្តាធិការ ដូច្នេះមុនឈានទៅស្វែងយល់ពីតួនាទីរបស់គាត់គប្បីស្វែងយល់ពីដើមកំណើតនៃការបង្កើតក្រឡាបញ្ជីនៅចំណុចខាងក្រោមជាមុនសិន។

### កថាខណ្ឌទី១ និយមន័យក្រឡាបញ្ជី

ពាក្យថាក្រឡាបញ្ជី នៅមិនទាន់មាននិយមន័យណាមួយឱ្យជាក់លក្ខៈនៅឡើយទេ។ ដោយសារតែច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីមិនទាន់បានប្រកាសឱ្យប្រើជាផ្លូវការនៅឡើយ។ ដូច្នេះពាក្យនេះគេតែងតែឱ្យនិយមផ្សេងៗទៅតាមបុគ្គលម្នាក់។

ពាក្យក្រឡាបញ្ជី នៅក្នុងវចនានុក្រម សម្តេចព្រះសង្ឃជនណាត បានឱ្យនិយមន័យថា ជាអ្នកមានឋានន្តរស័ករបស់មន្ត្រីជាន់កណ្តាលខាងតុលាការ ជាស្មៀនសម្រាប់កាន់កាប់បញ្ជី ឬកត់ត្រានៅសាលាជម្រះក្តី ឬលេខារបស់ចៅក្រម។ ដូច្នេះមានន័យថា ក្រឡាបញ្ជីជាអ្នកកត់ត្រា។[៥]

បើតាមសន្ទានុក្រមនីតិវិធីក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ពាក្យថា ក្រឡាបញ្ជីជាមន្ត្រីតុលាការដែលបំពេញមុខងារ ធានានូវដំណើរការនៃលេខាធិការដ្ឋានរបស់យុត្តាធិការ។[៦]

បើយោងតាមសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែល ជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌដែលមានកំណត់ក្នុងអត្ថបទច្បាប់ឬបទបញ្ជាធរមាន។ ក្រឡាបញ្ជីត្រូវស្ថិតនៅក្រោមបង្គាប់ចៅក្រម ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង សម្រាប់កិច្ចការផ្នែកយុត្តាធិការ។[៧]

---

[៥] វចនានុក្រសម្តេចសង្ឃរាជជួនណាត

[៦] ក្រមនីតិវិធីរដ្ឋប្បវេណី

[៧] សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃក្រឡាបញ្ជី ជំហាន់ទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦

### កថាខណ្ឌទី២ ដើមកំណើតនៃការបង្កើតក្រឡាបញ្ជី

ក្រោយពីសិក្សាស្រាវជ្រាវមកបានបង្ហាញឱ្យឃើញថា កាលពីសម័យអង្គរដើម្បីប្តឹងពីរឿងអ្វីមួយទៅព្រះមហាក្រត្រគេត្រូវដាក់ពាក្យមួយទៅព្រះអង្គតាមរយៈមន្ត្រីជាន់ខ្ពស់។ ការស៊ើបសួរត្រូវបានចាត់ធ្វើដោយមន្ត្រីម្នាក់ដោយកោះហៅ ភាគី និងកត់ត្រាការថ្លែងការរបស់ភាគីនោះ និងស្តាប់សាក្សី។[៩] ដោយ"ធម្មសាស្ត្រិន"ជាជំនួយឱ្យចៅក្រមដែលមានតួនាទីប្រហាក់ប្រហែលនឹងក្រឡាបញ្ជីបច្ចុប្បន្ន។ ធម្មសាស្ត្រិនជាអ្នកសូត្រច្បាប់ដែលចៅក្រមសួរឱ្យសូត្រមាត្រាច្បាប់ដែលទាក់ទងនឹងអង្គហេតុនៃរឿងក្តី។[៩]ការធ្វើទំនើបកម្មលើវិស័យយុត្តិធម៌នៅកម្ពុជា ដោយប្រទេសអាណានិគមបារាំងបន្តិចម្តងៗ ធ្វើឱ្យសញ្ញាណក្រឡាបញ្ជីលេចឡើងដំបូងក្នុងបទដ្ឋានគតិយុត្តិ លុះដល់សម័យបច្ចុប្បន្នប្រព័ន្ធច្បាប់ត្រូវបានវិសោធនកម្ម ក្រោយមកបានបង្កើតឱ្យមានច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ លុះដល់ឆ្នាំ១៩៩៨ ក៏មានការតែងតាំងក្រឡាបញ្ជីទៅបណ្តុះបណ្តាល។ ក្រោយមកនៅឆ្នាំ២០០៧ ប្រទេសកម្ពុជាបានវិសោធនកម្ម ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០២ និងបានកំណត់មុខងារ និងតួនាទីក្រឡាបញ្ជីជំនាន់ទី១ ហើយទទួលបានការបណ្តុះបណ្តាលនៅសាលាភូមិន្ទក្រឡាបញ្ជីនៃរាជសភាវិជ្ជាជីវៈតុលាការ លុះក្រោយមកក៏មានការជ្រើសរើសសិស្សក្រឡាបញ្ជីជាបន្តបន្ទាប់រហូតដល់បច្ចុប្បន្ន។

### កថាខណ្ឌទី៣ គោលបំណងនៃការបង្កើតក្រឡាបញ្ជី

ចៅក្រម និងព្រះរាជអាជ្ញាមានមុខងារជាច្រើនដែលត្រូវធ្វើ ដូចជាសម្រេចសេចក្តីដោយយុត្តិធម៌ ឯករាជ្យ និងគ្រប់គ្រងការងាររដ្ឋបាលផ្សេងៗទៀត។ គោលបំណងនៃការបង្កើតក្រឡាបញ្ជីគឺឱ្យមានអង្គការក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាជំនួយឱ្យអង្គការតុលាការ និងអង្គការអយ្យការសំដៅបង្កើតប្រសិទ្ធភាព និងគុណភាពនៃសេវាយុត្តិធម៌។[១០]ទោះបីជាយោងទៅតាមគោលការណ៍ឆាប់រហ័សរបស់ក្រសួងយុត្តិធម៌ដែលខិតខំជ្រើសរើសក្រឡាបញ្ជី ដើម្បីបណ្តុះបណ្តាលជារៀងរាល់ឆ្នាំយ៉ាងណាក្តី តែកកស្ទះការងារដោយសារតែមូលហេតុថា កង្វះក្រឡាបញ្ជីនៅតាមសាលដំបូងនៅខ្វះនៅឡើយ។ កត្តាដែលកង្វះក្រឡាបញ្ជីនោះមកពីការចាកចេញទៅប្រកបវិជ្ជាជីវៈមេធាវី។ដូច្នេះដើម្បីជួយទ្រទ្រង់សកម្មភាពការងារ សាលាដំបូង និងអយ្យការ បានទទួលមន្ត្រីជាប់កិច្ចសន្យា និងអ្នកហាត្ថការ ដើម្បីជួយការងារ និងសរសេរសាលក្រម-សាលក្រមស្ពាព ដែលជម្រះ

[៩]សៀវភៅស្តីពីអយ្យការ ប្រវត្តិនិងការរៀបចំ បោះពុម្ពលើទី១ ឆ្នាំ២០០៦ និពន្ធដោយលោក កុយ នាម និងលោកឡុង បញ្ញាវុឌ្ឍ ទំព័រ ៤០,៤១

ហើយមិនទាន់ធ្វើសាលដីកាបញ្ជូនទៅពន្ធនាគារ។ មានកម្រិតតិចតួចនៅឡើយ ដែលជាហេតុធ្វើឱ្យវិស័យយុត្តិធម៌មានភាពយឺតយ៉ាវ និងធ្វើឱ្យប្រជាពលរដ្ឋអស់ទំនុកចិត្តលើវិស័យមួយនេះ។ ជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញ បានទទួលសុំណុំរឿងយ៉ាងតិច បំផុត ២៥០០រឿងក្នុងមួយឆ្នាំ។

**កថាខណ្ឌទី៤ រចនាសម្ព័ន្ធសាលាដំបូងរាជធានី/ខេត្ត**

ក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបែងចែងជា ក្រឡាបញ្ជីអង្គការតុលាការ និងក្រឡាបញ្ជីអង្គការអយ្យការ។[11] ក្រឡាបញ្ជីនៃអង្គការតុលាការនៅតាមសាលាជម្រះក្តីនីមួយៗមានក្រឡាបញ្ជីអង្គតុលាការជាជំនួយនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ ក្រឡាបញ្ជីនៃសាលាជម្រះក្តីមួយដឹកនាំដោយនាយកក្រឡាបញ្ជី ១រូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នាយក្រឡាបញ្ជី និងក្រឡាបញ្ជីសាលាជម្រះក្តីមួយត្រូវស្ថិតនៅក្នុងអង្គភាពតែមួយ។[12] ក្រឡាបញ្ជីនៃអង្គការតុលាការនៅតាមអង្គការអយ្យការអមសាលជម្រះក្តីនីមួយៗ មានក្រឡាបញ្ជីអង្គការអយ្យការ ជាជំនួយនៅគ្រប់ដំណាក់កាលនៃនីតិវិធី។ ដូច្នេះយើងគប្បីស្វែងយល់ពីរចនាសម្ព័ន្ធសាលាដំបូងរាជធានី/ខេត្ត ដើម្បីបញ្ជាក់ពីតួអង្គក្រឡាបញ្ជីស្ថិតនៅក្រោមអំណាចអ្វីខ្លះ?

ដើម្បីឱ្យយល់កាន់តែច្បាស់ពីតួអង្គក្រឡាបញ្ជី ក្នុងការបំរើការងារវិស័យយុត្តិធម៌ផ្នែកព្រហ្មទណ្ឌនោះអ្នកអានគួរគប្បីអានផ្នែកខាងក្រោមះ

[10] មាត្រា ៥ សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃក្រឡាបញ្ជី ជំហាន់ទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦

[11] មាត្រា ៩ នៃសេចក្តីព្រាងច្បាប់ស្តីលក្ខន្តិកៈក្រឡាបញ្ជី ជំហានទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦




## ជំពូកទី២ ដំណាក់កាលមុនជំនុំជម្រះ

ដំណាក់កាលនេះជាដំណាក់កាលមួយដែលប្រគល់តួនាទីឱ្យស៊ើបអង្កេតជាបឋមជាមុនសិន ទើបអាចយកទៅជម្រះបាន។ ប្រសិនបើមិនមានការស៊ើបអង្កេតមិនជាក់លាក់នោះទេ ហាក់បីដូចជាការស៊ើបអង្កេតគ្មានភាពយុត្តិធម៌ព្រោះរឿងក្ដីជំនុំជម្រះនីមួយៗមានភាពស្មុគស្មាញជាច្រើនដែលត្រូវវែកញែកដូច្នេះដើម្បីឱ្យដំណើរការរឿងក្ដីមានភាពយុត្តិធម៌ មុនជំនុំជម្រះ គឺត្រូវប្រគល់តួនាទីទៅឱ្យព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរសាកសួរជាមុនសិន។ តើព្រះរាជអាជ្ញាជានរណា? ហើយអ្នកណាជាអ្នកជួយការងាររបស់ព្រះរាជាអាជ្ញា?

[១២] មាត្រា ១០ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ជំហានទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦

## ផ្នែកទី១ នៅដំណាក់កាលអយ្យការ

អង្គការអយ្យការ គឺជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[១៤] ដោយព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា អាចទទួលពាក្យបណ្តឹងពីរឿងក្តីព្រហ្មទណ្ឌណាមួយ។ ដោយពាក្យបណ្តឹងនីមួយៗអាចធ្វើឡើងដោយជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីផ្សេងៗទៀត ដែលមានសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីព្រហ្មទណ្ឌដូចជាមន្ត្រីគយ ឬក៏តតីយជនដែលដឹងឮពីបទល្មើស ឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

នៅតាមសាលាដំបូងនីមួយៗត្រូវមានអង្គការដែលដឹកនាំដោយព្រះរាជអាជ្ញាមួយរូប ឬព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។[១៥]

### កថាខណ្ឌទី១ តួនាទីក្រឡាបញ្ជីពេលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា

ដើម្បីដោះដោយស្រាយការងារជាច្រើនដែលត្រូវរកយុត្តិធម៌ជូនភាគីនោះ គឺត្រូវប្រើនីតិវិធីជាច្រើន ហេតុដូច្នេះហើយទើបមានសេចក្តីព្រាងច្បាប់ស្តីលក្ខន្តិកៈក្រឡាបញ្ជីបានចែងពីក្រឡាបញ្ជីអមអង្គអយ្យការ។ តើក្រឡាបញ្ជីអយ្យការមានតួនាទីបំពេញកិច្ចការងារអ្វីខ្លះ ដើម្បីជួយសម្រួលដល់ការងារព្រះរាជអាជ្ញា?

#### ១.១.តួនាទីទទួលសំណុំរឿង

ក្រឡាបញ្ជីអយ្យការ ជាអ្នកដែលទទួលបណ្តឹងពីមន្ត្រីនគរបាលយុត្តិធម៌ពីប្រជាពលរដ្ឋ ឬពីជនរងគ្រោះ អាណាព្យាបាលជនរងគ្រោះ ឬអង្គការផ្សេងៗ ពីព្រោះយុត្តាធិការព្រហ្មទណ្ឌក៏ទទួលបណ្តឹងពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ។

ជាទូទៅក្រឡាបញ្ជីជាអ្នកទទួលសំណុំរឿងពី នគរបាលយុត្តិធម៌គ្រប់គ្រងទាំងអស់រួមទាំងវត្ថុតាងផងដែរ។ ក្រឡាបញ្ជីជាអ្នកចុះលេខសំណុំរឿងចូលក្នុងសៀវភៅ ទទួលពាក្យបណ្តឹងព្រហ្មទណ្ឌឱ្យបានត្រឹមត្រូវ ដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងការពិនិត្យ។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជីមិនមានសិទ្ធិបដិសេធមិនទទួលយករបាយការណ៍ ឬបង្វិលតួនាទីឱ្យមន្ត្រីនគរបាល

[១៤] មាត្រា ៧៤ នៃសេចក្តីព្រាងច្បាប់ស្តីលក្ខន្តិកៈក្រឡាបញ្ជី ជំហានទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦
[១៥] មាត្រា ៧៥ នៃសេចក្តីព្រាងច្បាប់ស្តីលក្ខន្តិកៈក្រឡាបញ្ជី ជំហានទី៣ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦

យុត្តិធម៌កែប្រែ ឬបំពេញបន្ថែមនោះទេ។[16]ក្រឡាបញ្ជីត្រូវបញ្ជូនរបាយការណ៍ទៅព្រះរាអាជ្ញា ដើម្បីទទួលយោបល់ឱ្យធ្វើនិន្នេសបញ្ជាក់ពីអំពីការកោសលុប ទើបក្រឡាបញ្ជីធ្វើកំណត់ហេតុទទួលដឹងលើពីការកោសលុបពាក្យនោះ នៅលិខិតបញ្ជូនរបស់មន្ត្រីគយ ឬភ្នាក់ងារនគរបាលយុត្តិធម៌។ បន្ទាប់ក្រឡាបញ្ជីត្រូវពិនិត្យលើពាក្យបណ្ដឹងថា តើមានចុះខែឆ្នាំ ឬហត្ថលេខា ឬស្នាមមេដៃត្រឹមត្រូវហើយឬនៅ។[17] ម៉្យាងវិញទៀត ក្រឡាបញ្ជីត្រូវពិនិត្យមើលថា តើអ្នកណាជាអ្នកប្ដឹង? តើអ្នកប្ដឹងមានសមត្ថភាពខាងស្មារតីគ្រប់គ្រាន់ដែរឬទេ? បន្ទាប់មកទៀតរឿងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងដើម្បីត្រួតពិនិត្យ នឹងធ្វើការស៊ើបអង្កេតបឋម។

### ១.២.តួនាទីទទួលវត្ថុតាង

វត្ថុតាង ជារូបធាតុ ឬវត្ថុមានរូបដែលឆ្លុះបញ្ចាំងពីអត្ថិភាពនៃបទល្មើស។ វត្ថុតាង គឺជាអ្វីៗដែលបន្សល់ទុក ក្រោយបទល្មើសកើតឡើង ឬ ពេលបទល្មើសកំពុងចាប់ផ្ដើម។[18]ក្រោយពីមន្ត្រីនគរបាលរកឃើញវត្ថុតាងដែលមានការជាប់ពាក់ព័ន្ធបទល្មើស ឬជាតំរុយដែលសង្ស័យជាប់ពាក់ព័ន្ធបទល្មើសនោះ មន្ត្រីនគរបាលមានសិទ្ធិចាប់យកវត្ថុតាងនោះ ឧទាហរណ៍ៈ បទល្មើសជួញដូរគ្រឿងញៀន ដូច្នេះគ្រឿងញៀនទាំងនោះត្រូវចាប់យកទៅតម្កល់ទុកនៅនាយកដ្ឋាននៃបទល្មើស ចំណែកឯរថយន្តត្រូវប្រគល់ទៅឱ្យក្រឡាបញ្ជីអយ្យការ ដោយលិខិតមួយដែលហៅថា **កំណត់ហេតុចាប់យក**។ លិខិតនោះត្រូវមានឈ្មោះក្រឡាបញ្ជីដែលមានតួនាទីជាអ្នកបន្ទុកឃ្លាំងតម្កល់វត្ថុតាង និងឈ្មោះអ្នកតម្កល់វត្ថុជាមន្ត្រីមានសមត្ថកិច្ច។

ឧទាហរណ៍[19] ១.ក្រាមថ្លាពណ៌ស ទម្ងន់.......ក្រាម

២.ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងគ្រឿងញៀន ០១

៣.ទូរស័ព្ទដៃមានឈ្មោះម៉ាកសម្គាល់នៃទូរស័ព្ទនោះ

៤.សម្ភារៈសម្រាប់សេពគ្រឿងញៀន

[16] ហ៊ីង ធិឫទ្ធី សៀវភៅសម្រាប់ប្រជារាស្ត្រសាមញ្ញ ក្នុងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី ឆ្នាំ២០០៤

[17] បុគ្គលដែលមានអាយុក្រោយ ១៨ឆ្នាំ ឬ ឆ្កួតលីលាមិនអនុញ្ញាតឱ្យដាក់ពាក្យបណ្ដឹងបានទេ គឺត្រូវមានអ្នកតំណាង ឬអាណាព្យាបាលស្របច្បាប់។

[18] វចនានុក្រមច្បាប់ ខ្មែរ-អង្គគ្លេស រៀបរាងដោយ PHOU LAYSUN & PHOU VOUCHCHENG បោះពុម្ពលើកទី១ ឆ្នាំ ២០១២

[19] ឧបសម្ព័ន្ធទី១

សំខាន់បំផុតដែលមិនអាចខ្វះបាននោះត្រូវមាន ហត្ថលេខា និងឈ្មោះអ្នកប្រគល់ ហត្ថលេខា ឈ្មោះក្រឡាបញ្ជីទទួលបន្ទុក (ទទួលបានការឯកភាពពីព្រះរាជអាជ្ញាដោយមានឈ្មោះ និងហត្ថលេខា) ឈ្មោះជនជាប់សង្ស័យ និងស្នាមមេដៃ។

**១.៣.គំរូនាទីព្រាងដីកាផ្សេងៗ**

**ក.ដីកាកោះ**

ដីកាកោះ គឺជាប្រភេទលិខិតគតិយុត្តិ ដែលត្រូវប្រើប្រាស់ដើម្បីធ្វើការកោះហៅដល់ជនជាប់សង្ស័យ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឱ្យបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា។ ដោយក្នុងលិខិតនោះត្រូវ ទើបតែក្រសួងយុត្តិធម៌បង្កើតរូបមន្តដីកាកោះនេះឡើង ដើម្បីស្របតាមសញ្ញាណទ្រឹស្តីដែលបានកំណត់ដោយក្រមតម្រូវឱ្យក្រឡាបញ្ជី សរសេរមានទម្រង់ដូចខាងក្រោម៖[២០]

- ឈ្មោះ និងទីលំនៅបច្ចុប្បន្នរបស់បុគ្គលដែលត្រូវកោះហៅ
- ថ្ងៃ ខែ ឆ្នាំម៉ោង និងប្រាប់ពីទីកន្លែងត្រូវឱ្យបុគ្គលនោះទៅបង្ហាញនោះទៅបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា
- ប្រាប់ពីកម្មវត្ថុនៃការកោះហៅ
- ត្រូវបញ្ជាក់ប្រាប់សាមីបុគ្គលនោះឱ្យយកលិខិតផ្សេងៗ(លិខិតបញ្ជាក់អត្តសញ្ញាណឯកសារភស្តុតាង ឬសាក្សីទាក់ទងនឹងសំណុំរឿង)
- ឈ្មោះ និងឋានៈរបស់ព្រះរាជអាជ្ញាដែលចេញដីកាព្រមទាំងត្រូវមានចុះ ហត្ថលេខា និងបោះត្រា។

ក្រៅពីដីកាកោះ គឺក្រឡាបញ្ជីត្រូវកត់តែងលិខិតផ្សេងៗទៀត ទៅតាមការបង្គាប់បញ្ជារបស់ព្រះរាជអាជ្ញារួមមាន ដីកាបញ្ជាឱ្យចូលខ្លួន ដីកាចាត់តាំងអ្នកជំនាញ ដីកាទទួលយកមេធាវីឱ្យការពារកូនក្តី ដីកាបង្គាប់ឱ្យចុះពិនិត្យទីកន្លែងកើតហេតុ ដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន ដីការុករកវត្ថុតាង ដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានស្ថាពរ។

[២០] ឧបសម្ព័ន្ធទី២

### ខ.ដីកាសម្រេចបំបែកសំណុំរឿង

ក្រោយពីព្រះរាជអាជ្ញាពិនិត្យមើលទៅអង្គហេតុនៃបទល្មើសរួចហើយ ប្រសិនបើមានការលេចចេញនូវបទល្មើសពីរផ្សេងគ្នា នោះព្រះរាជអាជ្ញាបង្គាប់ឱ្យក្រឡាបញ្ជីចេញលិខិតមួយ ដែលជាលិខិតបំបែកសំណុំរឿងជាពីរ។ ក្នុងនោះផងដែរក្រឡាបញ្ជីត្រូវរៀបចំទៅតាមទម្រង់នៃលិខិត ដោយមានបញ្ជាក់ពីប្រភេទសំណុំរឿង និងលេខសំណុំរឿងដែលត្រូវបំបែក។ មានទាំងការយល់ឃើញរបស់ព្រះរាជអាជ្ញាដែលបញ្ជាក់ពីមូលហេតុនៃការបំបែកសំណុំរឿង។ដោយចុះលេខសំណុំរឿង ដោយមានការប្រុងប្រយ័ត្នរួមទាំងប្រមូលវត្ថុតាង និងឯកសារផ្សេងៗដែលពាក់ព័ន្ធបញ្ជូនក្នុងសំណុំរឿងនីមួយៗ។[២១]

ឧទាហរណ៍៖ រឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០១-០១-២០១៩

-ជនជាប់សង្ស័យឈ្មោះ ក ជាប់ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិA ឃុំB ស្រុកC ខេត្តD កាលថ្ងៃទី០១-១២-២០១៨

-ជនជាប់សង្ស័យឈ្មោះ ខ ជាប់ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិZ ឃុំY ស្រុកX ខេត្តW កាលពីថ្ងៃទី០៥-១២-២០១៨

**យល់ឃើញ**

-សំណុំរឿងនេះមានបទល្មើសផ្សេងៗពីគ្នា.......

**ហេតុដូច្នេះសម្រេច**

-បំបែកសំណុំរឿងព្រហ្មទណ្ឌលេខ១១ ចុះថ្ងៃទី០១-០១-២០១៩ ជា០២ទៅតាមបទល្មើសនីមួយៗ

-បង្គាប់មកក្រឡាបញ្ជីចាត់ចែង និងបំបែកសំណុំរឿងនេះ

### គ.ប្រភេទដីកាប្រើនៅអយ្យការ

ព្រះរាជអាជ្ញា ជាដើមបណ្តឹងអាជ្ញាដែលការពារផលប្រយោជន៍សង្គម។ ក្រៅពីនេះព្រះរាជអាជ្ញាមានសិទ្ធិចេញដីកាផ្សេងៗទៅតាមច្បាប់ដែលបានកំណត់ទុក។ ដូច្នេះក្រឡាបញ្ជីអយ្យការតម្រូវឱ្យមានការយល់ដឹងក្នុងការចេញប្រភេទដីកាទៅតាមកាលៈទេសដែលត្រូវប្រើ។

[២១] ឧបសម្ព័ន្ធទី៣

ដីកាទាំងនោះរួមមាន[២២]៖

- ដីកាបង្គាប់ឱ្យចាប់ខ្លួន
- ដីកាបញ្ជាប់ឱ្យចាប់ខ្លួន
- ដីកាបង្គាប់ឱ្យនាំខ្លួន
- ដីកាបញ្ជាប់ឱ្យនាំខ្លួន
- ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន
- ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន
- ដីកាសម្រេចមិនឃុំខ្លួន
- ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ
- លិខិតជូនដំណឹង
- ដីកាកោះ
- ដីកាចាត់តាំងអ្នកជំនាញ
- ដីកាបង្គាប់ឱ្យឆែកឆេរលំនៅដ្ឋាន
- ដីកាបង្គាប់ឱ្យចុះពិនិត្យកន្លែងកើតហេតុ
- ដីកាផ្ទេរសមត្ថកិច្ច
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែម
- ដីកាបំបែកសំណុំរឿង
- ដីកាសន្និដ្ឋានស្ថាពរ

### ឃ.តួនាទីសរសេរកំណត់ហេតុ

កំណត់ហេតុជាអ្វី? កំណត់ហេតុ គឺជាសេចក្ដីកត់សម្គាល់ហេតុទាំងឡាយដែលកើតមានឡើងនៅពេលមានការសាកសួរពីព្រះរាជអាជ្ញា។ ក្រឡាបញ្ជីជាអ្នកកត់ត្រារាល់ពត៌មានតាមរយៈការសាកសួរ ឬស្ដាប់ចម្លើយរបស់ជនសង្ស័យ ឬជនល្មើស ឬដើមបណ្ដឹង ឬសាក្សី នៅក្នុងកំណត់ហេតុដែលមានការដឹកនាំក្នុងការធ្វើកំណត់ហេតុដោយព្រះរាជាអាជ្ញា។ ទម្រង់កំណត់ហេតុសម្រាប់ទិន្នភាពនៃការអនុវត្តគឺមាន ការចុះហត្ថលេខារបស់ក្រឡាបញ្ជីអមតំណាងអយ្យការ។

ចំពោះការសាកសួរយកចម្លើយ ក្រឡាបញ្ជីមិនត្រូវអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញ/ចូលបន្ទប់សួរចម្លើយទេ។

- ករណីជនសង្ស័យជាអនីតិជន (ជូនដំណឹងទៅអាណាព្យាបាល)

[២២] ឧបសម្ព័ន្ធទី៤ (ដកស្រង់ចេញពីមេរៀន និងសំណុំរឿងនៅសាលាឧទ្ធរណ៍)

- ករណីជនសង្ស័យជាជនបរទេស (រកអ្នកបកប្រែ)

ក្រឡាបញ្ជីត្រូវសរសេរដោយមានឃ្លាប្រយោគ និងមិនត្រូវធ្វើការដកឃ្លាឃ្លាតពីគ្នាពេក ឬរំលងបន្ទាត់ដែលអាចបណ្តាលឱ្យ មានការបំពេញបន្ថែមតួអក្សរជាយថាហេតុពីសំណាក់អ្នកដទៃ។ បើមានខណ្ឌត្រូវធ្វើការចុះដើមបន្ទាត់ និងត្រូវសរសេរខណ្ឌ និងអូសបន្ទាត់ពីមុខ។ បើសរសេរមិនអស់សន្លឹកហើយនៅសល់ត្រូវឆូតរាងអក្សរ Z។[២៣]

ក្រៅពីនេះក្រឡាបញ្ជីត្រូវរៀបចំ តំប៉ុងសម្រាប់ផ្តិតមេដៃ ក្រដាសសម្រាប់កត់ត្រា និងសម្រាប់គូសវាសធ្វើជាផែនទីកំណត់ទីតាំង។ ក្រោយពីពេលបញ្ចប់ការសួរយកចម្លើយពីជនសង្ស័យរួចហើយ ជននោះត្រូវបានព្រះរាជអាជ្ញារកឃើញថាមានពិរុទ្ធភាពហើយ ព្រះរាជអាជ្ញាផ្តើមធ្វើការចោទប្រកាន់ តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរពេលនេះ ក្រឡាបញ្ជីត្រូវប្រគល់ខ្លួនជនសង្ស័យ និងសំណុំរឿងព្រមទាំងភស្តុតាងទៅឱ្យចៅក្រមស៊ើបសួរតាមនីតិវិធីដើម្បីចាត់វិធានការបន្ត។

## កថាខណ្ឌទី២ តួនាទីក្រឡាបញ្ជីក្រោយពេលស៊ើបអង្កេតអយ្យការ

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ (តម្កល់រឿងឥតចាត់ការ) ឬអាចមានជម្រើសចោទប្រកាន់ (បញ្ជូនរឿងទៅស៊ើបសួរ)។[២៤] ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បទព្រហ្មទណ្ឌ ដោយការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬដោយតាមនីតិវិធី បង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមៗ ឬដោយការបើកការស៊ើបសួរ។[២៥]

### ២.១.ករណីមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា

ក្រោយពីការសាកសួរដេញដោលចំពោះមុខ និងពិនិត្យមើលតាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌រួចមក។ ប្រសិនបើពិនិត្យមើលទៅតាមអង្គហេតុ ដែលកើតឡើងនោះមិនជារឿងព្រហ្មទណ្ឌ ដោយសារមានភស្តុតាងណាមួយគួរឱ្យជឿថា ពិតជាមានបទល្មើសកើតឡើងនោះ (អវត្តមានជនល្មើស) ឬ មានហេតុផលផ្សេងៗទៀត។ ដូចនេះព្រះរាជអាជ្ញាបង្គាប់ឱ្យក្រឡាបញ្ជីចេញលិខិតពីរ គឺតាក់តែងដីកាតម្កល់រឿងទុកឥតចាត់ការ(ក) និងជូនដំណឹងទៅភាគីពាក់ព័ន្ធ(ខ)។

---

[២៣] យោបលក្រឡាបញ្ជីសាលាឧទ្ធរណ៍ (អតីតក្រឡាបញ្ជីខេត្តកំពត) ឧទាហរណ៍ ឧបសម្ព័ន្ធទី ៥

[២៤] មាត្រា ៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ក.តាក់តែងដីកាតម្កល់រឿងទុកឥតចាត់ការ

ក្រោយពេលព្រះរាជអាជ្ញាបំពេញការងាររបស់ខ្លួនចប់សព្វគ្រប់ហើយ នោះព្រះរាជអាជ្ញាបង្គាប់ឱ្យក្រឡាបញ្ជីតាក់តែងលិខិតមួយ ដើម្បីបញ្ចូលទៅក្នុងសំណុំរឿងនោះ គឺដីកាតម្កល់រឿងទុកឥតចាត់ការ។ ដោយមានបញ្ជាក់ទាំងសំអាងច្បាប់ និងសំអាងហេតុ។[២៦] ក្រឡាបញ្ជីត្រូវវាយកុំព្យូទ័រទៅតាមទម្រង់នៃប្រភេទដីកាតាមការណែនាំរបស់ក្រសួង។ ឧទាហរណ៍មានក្នុងឧបសម្ព័ន្ធ[២៧]

### ខ.ជូនដំណឹងទៅភាគីពាក់ព័ន្ធ

រឿងហេតុដែលកើតឡើងអាចមានភាគីពាក់ព័ន្ធ (ដើមបណ្ដឹង)ច្រើន ឬ តិចទៅតាមប្រភេទនៃបទល្មើសដែលកើតឡើង ជួនកាលអាចគ្មានដើមបណ្ដឹងទៀតផង(បណ្ដឹងអាជ្ញា)។

កាលណាបណ្ដឹងណាមួយត្រូវតម្កល់រឿងទុកឥតចាត់ការ។ ក្រឡាបញ្ជីត្រូវធ្វើសេចក្ដីជូនដំណឹងឱ្យភាគី ដើម្បីឱ្យភាគីអាចធ្វើការបណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ការតវ៉ានឹងដីកាតម្កល់ រឿងឥតចាត់ការត្រូវធ្វើក្នុងរយៈពេល ០២ខែគិតពីថ្ងៃទទួលដំណឹងពីដីកានោះ។ ឧទារហណ៍ មាននៅក្នុងឧបសម្ព័ន្ធ [២៨]

ក្រឡាបញ្ជីបញ្ជូនដីកាទៅអ្នកដែលពាក់ព័ន្ធទាំងឡាយតាមខ្លឹមសារនៃដីកា។ ចំនួនដីកាដែលក្រឡាបញ្ជី ត្រូវសរសេរមានការប្រែប្រួលទៅតាមភាគីពាក់ព័ន្ធ។ ក្រោយពេលដែលដីកាបញ្ជូននេះត្រូវបានចុះហត្ថលេខាដោយជនដែលទទួលដីកា។ ក្រឡាបញ្ជីប្រគល់ដីកានេះទៅអយ្យការ និងដាក់បញ្ជូនទៅក្នុងសំណុំរឿង។

### ២.២.ករណីចោទប្រកាន់របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាជាម្ចាស់បណ្ដឹងអាជ្ញា ដោយមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ ព្រះរាជអាជ្ញាត្រូវធានាឱ្យបានថា ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌមានគ្រប់គ្រាន់ហើយត្រូវវាយតម្លៃកំណត់បទល្មើសសមស្របទៅនឹងអំពើដែលបានប្រព្រឹត្ត បូករួមជាមួយភស្តុតាងធនល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្ត។ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម (មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) **ការបើកធ្វើការស៊ើបសួរ(ក) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់(ខ)**

---

[២៥] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[២៦] មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[២៧] ឧបសម្ព័ន្ធទី ៦
[២៨] ឧបសម្ព័ន្ធទី ៧

## ក.ការបើកការស៊ើបសួរ

ក្នុងការបើកការស៊ើបសួរនេះអាចជាបទឧក្រិដ្ឋ ដែលមានភាពស្មុគស្មាញ ដូច្នេះព្រះរាជអាជ្ញាបង្គាប់ឱ្យក្រឡាបញ្ជីធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកានេះព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយក្រឡាបញ្ជីត្រូវតែកាត់តាមទម្រង់ដូចខាងក្រោម[២៩]

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលបានកំណត់ នឹងបង្ក្រាបបទល្មើស
- ឈ្មោះ បុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន

ក្រឡាបញ្ជីត្រូវឱ្យព្រះរាជអាជ្ញាត្រួតពិនិត្យ មុនព្រះរាជអាជ្ញាចុះហត្ថលេខា និងវ៉ាយត្រាព្រះរាជអាជ្ញា។ ទម្រង់នេះមានលក្ខណៈដាច់ខាតដែលត្រូវតែគោរព បើពុំដូច្នេះទេដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

## ខ.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

មុនបញ្ជូនរឿងទៅជម្រះផ្ទាល់ ឬការជម្រះភ្លាមនោះ ក្រឡាបញ្ជីត្រូវពិនិត្យមើលសំណុំរឿង និងកំណត់អត្តសញ្ញាណជនជាប់ចោទឱ្យបានច្បាស់ និងរៀបចំឯកសារឱ្យមានរបៀបរៀបរយតាមលំដាប់ ដើម្បីងាយស្រួលអាន។

ក្រឡាបញ្ជីត្រូវបញ្ជូនដីកាកោះមុនការបរិច្ឆេទសវនាការគឺ៖[៣០]

- ១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅដែនសមត្ថកិច្ចរបស់តុលាការ
- ២០(ម្ភៃ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់ នៅកន្លែងផ្សេងទៀតក្នុងទឹកដីនៃព្រះរាជណាចក្រកម្ពុជា
- ២(ពីរ)ខែ ប្រសិនបើជនជាប់ចោទរស់នៅរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣(បី)ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទឹកន្លែងដទៃផ្សេងគ្នា។

[២៩] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣០] មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងករណីបទល្មើសលហុ និងបទល្មើសមជ្ឈិម ព្រះរាជអាជ្ញាអាចសមស្របបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន ដោយបង្គាប់ឱ្យក្រឡាបញ្ជីព្រាងដីកាកោះបញ្ជូនរឿងទៅជំម្រះ តាមគំរូបមន្តដែលបានណែនាំ និងគោរពថេរវេលានៃការកោះហៅឱ្យបានត្រឹមត្រូវ។ ដោយដើមដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅដ្ឋានរបស់ជនជាប់ចោទ ត្រូវតែមានចុះការបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។[៣១]

## ផ្នែកទី២ នៅដំណាក់កាលចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ ត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។[៣២]នៅដំណាក់កាលនោះក្រឡាបញ្ជីត្រូវចូលរួមជាមួយចៅក្រមស៊ើបសួរ ដើម្បីកត់ត្រាកំណត់ហេតុ តាក់តែងដីកាផ្សេងៗ ទទួលពាក្យសុំរបស់ភាគី ចម្លងដីកា ជូនដំណឹងដល់ភាគីអំពីដីកាកោះជនត្រូវចោទ សាក្សី អ្នកជំនាញ មេធាវី ទទួលបណ្ដឹងឧទ្ធរណ៍របស់ភាគី គ្រប់គ្រងថែរក្សាឯកសារនៃសំណុំរឿង។

### កថាខណ្ឌទី១ តួនាទីក្រឡាបញ្ជីមុនពេលស៊ើបសួរ

នៅពេលទទួលបានសំណុំរឿងស៊ើបសួរ ប្រធានតុលាការជាអ្នកចាត់តាំងចៅក្រមស៊ើបសួរទៅតាមលំដាប់លេខស្ទីត។ក្រោយពេលបានទទួលសំណុំរឿងតាមការចាត់តាំងពីប្រធានតុលាការហើយចៅក្រមស៊ើបសួរត្រូវចាត់តាំងក្រឡាបញ្ជីមួយរូបឱ្យទទួលការចាត់ការសំណុំរឿងនេះតាមនីតិវិធី។ក្រឡាបញ្ជីត្រូវទទួលបានការចាត់តាំងនោះ ត្រូវមានភារកិច្ចបំពេញកិច្ចនីតិវិធីជាច្រើនដូចជា៖

#### ១.១.គោលការណ៍រក្សាការសម្ងាត់នៃការស៊ើបសួរ

ជាគោលការណ៍មិនថា នរណា ឬអ្នកណាដែលជាអ្នកវិជ្ជាជីវៈត្រូវតែរក្សាការសម្ងាត់។ ជាក់ស្ដែងការស៊ើបសួរត្រូវតែជាការសម្ងាត់។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរជាពិសេស ចៅក្រម, មេធាវី,ក្រឡាបញ្ជី,នគរបាលយុត្តិធម៌,មន្ត្រីកងរាជអាវុធហត្ថ,មន្ត្រីរាជការ,អ្នក

---

[៣១] មាត្រា ៤៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៣២] មាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជំនាញ,អ្នកបកប្រែ,គ្រូពេទ្យនិងបុគ្គលដែលមានសមត្ថកិច្ច។ ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[៣៣]

ជាទូទៅក្រឡាបញ្ជីជាអ្នកទទួលសំណុំរឿង និងអ្នកថែរក្សាសំណុំរឿង អាចនិយាយបានថា ក្រឡាបញ្ជីជាអ្នកដឹងរឿងជាច្រើនពីភាគីមិនថា រឿងល្អ ឬអាក្រក់ពីភាគី។ ដូច្នេះក្រឡាបញ្ជីមិនត្រូវយកការសម្ងាត់របស់ភាគី ឬ មេធាវីម្ខាងទៀត ប្រាប់ភាគីម្ខាងទៀតបានទេ។ ការបំពានទៅនឹងការសម្ងាត់នៃការស៊ើបសួរ ឬ ការធ្វើឱ្យបែកធ្លាយកិច្ចការផ្ទៃក្នុងរបស់តុលាការ។ ជាគោលការណ៍របស់ក្រសួងយុត្តិធម៌មានទណ្ឌកម្ម និងវិន័យទៅតាមអំពើដែលក្រឡាបញ្ជីបានប្រព្រឹត្ត។

ឧទាហរណ៍៖ ក្នុងករណីរឿង ឃាតកម្ម ក្រោយចៅក្រមស៊ើបសួរ សាកសួរលេចចេញអង្គហេតុនោះបន្ទុកនោះ ក្រឡាបញ្ជីមិនអាចយកការសម្ងាត់ទៅប្រាប់មេធាវីការពារឱ្យជនជាប់ត្រូវចោទបានទេ។

### ១.២.ចុះលេខសំណុំរឿងនៅក្នុងសៀវភៅនានា

#### ក.សៀវភៅចុះសំណុំរឿងព្រហ្មទណ្ឌរបស់ប្រធានតុលាការ

ក្រោយពេលបានទទួលសំណុំរឿងតាមការចាត់តាំងពីប្រធានតុលាការ ក្រឡាបញ្ជីត្រូវយកសំណុំរឿងទៅក្នុងសៀវភៅចុះសំណុំរឿងព្រហ្មទណ្ឌរបស់ប្រធានតុលាការដែលប្រើប្រាស់សម្រាប់ចុះយកលេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿងស៊ើបសួរ ដើម្បីងាយស្រួលដល់ប្រធានតុលាការតាមដានសកម្មភាពនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរនៃបន្ទប់នីមួយៗលើសំណុំរឿងព្រហ្មទណ្ឌដែលខ្លួនបានចាត់តាំងឱ្យស៊ើបសួរ។

#### ខ.សៀវភៅចុះសំណុំរឿងរបស់ចៅក្រមស៊ើបសួរ

ជាទូទៅចៅក្រមស៊ើបសួរតែងតែមានសៀវភៅចុះសំណុំរឿងព្រហ្មទណ្ឌរាងៗខ្លួនសម្រាប់ចុះសំណុំរឿងស៊ើបសួរដែលទទួលបាន។ ក្នុងការអនុវត្តបន្ទាប់របស់ក្រឡាបញ្ជីបានចុះសំណុំរឿងព្រហ្មទណ្ឌរួចរាល់នៅក្នុងសៀវភៅរបស់ប្រធានតុលាការ ក្រឡាបញ្ជីត្រូវយកសំណុំរឿងមកចុះយកលេខ ថ្ងៃ ខែ ឆ្នាំ នៅក្នុងសៀវភៅព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរតាមបន្ទប់មួយទៀត ដើម្បីតាមដានសកម្មភាពស៊ើបសួរចំពោះសំណុំរឿងដែលខ្លួនបានទទួល។

---

[៣៣] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### គ.សៀវភៅពិសេស

នៅក្នុងកិច្ចនៃនីតិស៊ើបសួររាល់ដីកាសម្រេច និងសេចក្ដីសម្រេចផ្សេងៗដែលចេញដោយចៅក្រមស៊ើបសួរ ក្រឡាបញ្ជីត្រូវយកទៅចុះយកលេខ ថ្ងៃ ខែ ឆ្នាំ ក្នុងសៀវភៅពិសេសនេះទាំងអស់។

## ១.៣.ការតាក់តែងដីកាផ្សេងៗ

### ក.ដីកាចាត់តាំងរបស់ចៅក្រមស៊ើបសួរ

ដីកាចាត់តាំងចៅក្រមស៊ើបសួរចេញដោយប្រធានសាលាដំបូង ឬ អនុប្រធានសាលាដំបូង (មានការផ្ទេរសិទ្ធិពីប្រធាន) ចាត់តាំងចៅក្រមស៊ើបសួររូបណាឱ្យទទួលបន្ទុកស៊ើបសួររឿងក្ដីព្រហ្មទណ្ឌទៅតាមវេននៃការបែងចែកសំណុំរឿង ហើយក្រឡាបញ្ជីជាអ្នកដែលមានភារកិច្ចរៀបចំទម្រង់ដីកានេះ។

### ខ.ដីកាផ្ទេរសមត្ថកិច្ច

សមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរបានតែចំពោះកន្លែងបទល្មើស ទីលំនៅ ឬទីសំណាក់ ឬនាទីកន្លែងចាប់ខ្លួនរបស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។[៣៩]ដូច្នេះនៅក្នុងករណីដែលចៅក្រមស៊ើបសួរកំពុងស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌណាមួយ ហើយមានគេប្ដឹង ឬមានការយល់ឃើញដោយខ្លួនឯងថា សំណុំរឿងដែលខ្លួនកំពុងស៊ើបសួរមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួននោះទេ ចៅក្រមស៊ើបសួររូបនោះអាចចេញដីកាផ្ទេរសមត្ថកិច្ចទៅឱ្យចៅក្រមស៊ើបសួរនៃតុលាការផ្សេងទៀត។

### គ.ដីកាសម្រេច និងដីកាបង្គាប់

ក្នុងការអនុវត្តសព្វថ្ងៃរាល់ដីកាសម្រេច ដីកាបង្គាប់ ឬលិខិតផ្សេងៗរបស់ចៅក្រមស៊ើបសួរដែលត្រូវចេញនៅក្នុងកិច្ចស៊ើបសួរ ក្រឡាបញ្ជីជាអ្នកព្រាងជូនចៅក្រមស៊ើបសួរទាំងអស់ក្នុងករណីដែលចៅក្រមបង្គាប់បញ្ជា ហើយរាល់ដីកាទាំងនោះក្រឡាបញ្ជីត្រូវចុះយកលេខដីកាពីសៀវភៅពិសេសផ្ទាល់របស់ចៅក្រមស៊ើបសួរ

[៣៩]មាត្រា ១២៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

**ឃ.ដីកាកោះ**

ក្រឡាបញ្ជីត្រូវព្រាងដីកាកោះ ០២ ច្បាប់ ដោយ ០១ ច្បាប់ត្រូវរក្សាទុកនៅក្នុងសំណុំរឿងបង្កាទុក និង ០១ ច្បាប់ ទៀតត្រូវផ្ញើទៅបុគ្គលដែលធ្វើការកោះហៅ។ ក្នុងទម្រង់នៃដីកាកោះ ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវអត្តសញ្ញាណរបស់បុគ្គលដែលត្រូវធ្វើការកោះហៅ សញ្ញាណនៃរឿងក្តី និងត្រូវប្រាប់អំពីឋានៈរបស់បុគ្គល ដែលនឹងត្រូវចូលឆ្លើយបំភ្លឺ។ ក្រឡាបញ្ជីត្រូវយកដីកាកោះនោះឱ្យចៅក្រមស៊ើបសួរចុះហត្ថលេខាព្រមទាំងឈ្មោះ និងបោះត្រានៅលើដីកាកោះនោះ បន្ទាប់បកយកលេខនៃដីកាកោះពីសៀវភៅពិសេសចុះលេខសំណុំរឿងស៊ើបសួរនៃបន្ទប់ចៅក្រមដែលទទួលបន្ទុក ទើបធ្វើការបញ្ជូនដីកាកោះនោះ។

**ង.ដីកាបញ្ជូន**

ដីកាបញ្ជូនត្រូវធ្វើជា ០២ច្បាប់តម្កល់ទុកក្នុងសំណុំរឿងបង្កាទុក មួយច្បាប់ទៀតទុកឱ្យអ្នកទទួល ដើម្បីឱ្យភាគីដែលទទួលបានដីកាកោះចុះហត្ថលេខា ឬផ្តិតតម្រាមដៃ ដើម្បីបញ្ជាក់ថាបានទទួលការកោះហៅត្រឹមត្រូវតាមច្បាប់ ហើយដីកាបញ្ជូននោះត្រូវបង្វិលត្រលប់មកក្រឡាបញ្ជីរក្សាទុកក្នុងសំណុំរឿង។ ចំពោះដីកាបញ្ជូននេះត្រូវ ចុះហត្ថលេខា ការបោះត្រា និងការយល់លេខដីកាមានលក្ខណៈដូចគ្នា នឹង ដីកាកោះដែរ។

**កថាខណ្ឌទី២ តួនាទីក្រឡាបញ្ជីក្នុងដំណើរការនៃនីតិវិធីស៊ើបសួរ**

**២.១.របៀបការហៅ និងការជូនដំណឹង**

ជនត្រូវចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី និងសាក្សី អាចធ្វើការកោះហៅបានគ្រប់ពេលវេលា និងតាមគ្រប់មធ្យោបាយដោយក្រឡាបញ្ជី។ ចំពោះការអនុវត្តនៅសាលាដំបូងខេត្តកណ្តាលការបញ្ជូនដីកាកោះ ក្រឡាបញ្ជីធ្វើតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំណែកករណីជនត្រូវចោទនៅក្នុងឃុំបណ្តោះអាសន្ន ការកោះហៅធ្វើតាមរយៈប្រធានពន្ធនាគារ តាមរយៈទូរស័ព្ទ ឬដោយផ្ទាល់មាត់។

**២.២.អំពីការកោះហៅមេធាវី**

ការកោះហៅមេធាវីក្រឡាបញ្ជីមួយចំនួនធ្វើជាលិខិតអញ្ជើញមេធាវី។ ចំណែកឯការបញ្ជូនដីកាកោះហៅមេធាវី ក្រឡាបញ្ជីធ្វើតាមរយៈប្រៃសណីយ៍ហើយក៏មានមួយចំនួនធ្វើតាមរយៈ

ផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទតែម្តង។ ចំពោះរយៈពេលបញ្ជូនដីកាកោះ ក្រឡាបញ្ជីភាគច្រើន នៅសាលាដំបូងខេត្តធ្វើការកោះហៅមេធាវី មុនការសួរចម្លើយមួយសប្តាហ៍។

**២.៣.ចុះកន្លែងកើតហេតុ**

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែង ជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីតុលាការដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ដើម្បីធ្វើការពិនិត្យ សម្ភារៈ ឆែកឆេរ និងចាប់យកវត្ថុតាង។ ចៅក្រមស៊ីបសួរជូនដំណឹងទៅព្រះរាជអាជ្ញា ដែលអាចរួមដំណើរជាមួយខ្លួន។ ក្រឡាបញ្ជីជាជំនួញការរបស់ចៅក្រមស៊ើបសួរ ជាអ្នកធ្វើកំណត់ហេតុស្តីពីការចុះទីកន្លែងកើតហេតុ និងកិច្ចដែលបានបំពេញនៅកន្លែងនោះ ប៉ុន្តែប្រសិនបើមានការចាំបាច់នៃការស៊ើបសួរ តម្រូវឱ្យចៅក្រមស៊ើបសួរអាចចុះដល់កន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល ដោយជូនដំណឹងជាមុនទៅព្រះរាជអាជ្ញាអមសាលាដំបូង នៅដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ។[៣៥]ក្រឡាបញ្ជីចុះអមជាមួយចៅក្រមស៊ើបសួរ ការឆែកឆេរ ឬរុករកវត្ថុតាង ប៉ុន្តែការឆែកឆេរនេះត្រូវធ្វើនៅ ចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងត្រូវធ្វើនៅចំពោះមុខសាក្សី២ (ពីរ) នាក់ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬ ជាកងកម្លាំង ដែលជាកម្លាំងរួមប្រតិបត្តិការណ៍ក្នុងការឆែកឆេរនោះឡើយ។ ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង៦ (ប្រាំមួយ) ព្រឹកនឹង ក្រោយម៉ោង ១៨ (ដប់ប្រាំបី)បានទេ លើកលែងតែៈ

-ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកជំហរដល់សាធារណៈជន

-ក្នុងករណីឆែកឆេរនៅទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ ក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដោយមានការចុះហត្ថលេខារបស់ខ្លួន និងរបស់ចៅក្រមស៊ើបសួរព្រមទាំងអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២(ពីរ) នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ ក្នុងករណីធ្វើការឆែកឆេរប្រព្រឹត្តទៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬប្រតិភូនៃប្រធានគណៈមេធាវីនេះ។ ចៅក្រមស៊ើបសួរអាចចាប់យកភស្តុតា

[៣៥] មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ង។ចៅក្រមស៊ើបសួរបង្គាប់ឱ្យក្រឡាបញ្ជីបិទស្លាកលើវត្ថុតាង។ ក្រឡាបញ្ជីត្រូវបង្ហាញវត្ថុតាងដែលចាប់យក បង្ហាញអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២(ពីរ) នាក់។ ក្រឡាបញ្ជីធ្វើកំណត់ហេតុស្ដីពីការចាប់យកវត្ថុតាង ដែលមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ស្ដីពីការចាប់យកវត្ថុតាងត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចៅក្រមស៊ើបសួររួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។[៣៦]ក្រឡាបញ្ជី និងចៅក្រមស៊ើបសួរអាចចុះទៅលំនៅឋាន ឬ ទីកន្លែងសាក្សីនោះដើម្បីទទួលយកចម្លើយ ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរមកសាលាដំបូងខេត្តបាន។[៣៧]

### ២.៤.ដឹកនាំសម្បថសាក្សី

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងនៃតុលាការនីមួយៗ។ មុននឹងចាប់ផ្តើមធ្វើសម្បថត្រូវអុជទាន ធូប បូជាចំពោះមុខវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវធ្វើសម្បថនោះ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្ធវាទខ្លាំងៗ។ច្បាស់ៗឱ្យអ្នកធ្វើសម្បថស្តាប់ រួចអាន ពាក្យសច្ចាប្រណិធានឱ្យអ្នកធ្វើសម្បថថាតាម។ ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំនត់ហេតុដែលបានឱ្យស្បថនោះបញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយសេចក្តីបានចេញវាចារឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។[៣៨]

#### ប្រារព្ធវាទ

បពិត្រអស់ទ្រព្យ អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតា ក្របាមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះ ជីវីវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតី ក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់ត្រូវឱ្យយកអ្នកទាំងអស់នេះ មកធ្វើជាសាក្សី ឱ្យឆ្លើយឱ្យបាន ទៀងត្រង់តាមពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្យ អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឲ្យព្រាត់ប្រាស់ឪពុកម្តាយ បងប្អូន កូនចៅ ឱ្យរហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ។ បើ

---

[៣៦] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៣៧] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អ្នកណាឆ្លើយឲ្យការណ៍ដោយមិនពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀងព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា តាយទេញ និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឲ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់ រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តី បំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឲ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោង យ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

**សាក្សីដែលអនុញ្ញាតឱ្យស្បថសម្បថ[៣៩]**

- ឪពុក ម្តាយ និង បុព្វជនគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ
- កុមារអាយុតិចជាង ១៤ឆ្នាំ។

[៣៨] ឧបសម្ព័ន្ធទី ១០

[៣៩] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.៥.ភារកិច្ចរបស់ក្រឡាបញ្ជីបំពេញកិច្ចស៊ើបសួរ

### ក.ការចូលបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទករណីជាក់ស្តែង

ការចូលបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទ ត្រូវមានវត្តមានរបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និងមេធាវី ហើយតម្រូវឱ្យចៅក្រមមស៊ើបសួរ ពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននោះអំពីរឿងរ៉ាវដែលបានចោទប្រកាន់ និងប្រាប់អំពីបទល្មើសដែលកំណត់ដោយច្បាប់ ព្រមទាំងសិទ្ធិទាំងឡាយដែលខ្លួនបានសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យ សម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ឬមិនឃុំខ្លួនជនត្រូវចោទ[៤០]ជាក់ស្តែងពេលខ្លះចៅក្រមស៊ើសួរមួយចំនួនមានវត្តមាន និងអនុវត្តក្នុងករណីនេះ ចំពោះតែជនត្រូវចោទមានមេធាវីការពារក្តីប៉ុណ្ណោះ ដោយចៅក្រមគ្រាន់តែដៅសំណួរ និងបង្គាប់ដល់ក្រឡាបញ្ជីឱ្យសួរនូវចំណុចដែលទាក់ទងនឹងកិច្ចស៊ើបសួរ ដោយសារតែចៅក្រមស៊ើបសួរមានការមមាញឹកនឹងសំណុំរឿង។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវបំពេញកិច្ចការលម្អិតដូចខាងក្រោម៖

- សរសេរកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង[៤១]

ការបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទ ត្រូវមានវត្តមានរបស់ចៅក្រមស៊ើបសួរដែលទទួលបានបន្ទុកលើរឿងក្តី។ នាពេលនោះក្រឡាបញ្ជីត្រូវមានវត្តមានរបស់ចៅក្រមស៊ើបសួរទៅក្នុងកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងនោះ។ ក្រោយពីបញ្ចប់កំណត់ហេតុ ក្រឡាបញ្ជីត្រូវប្រគល់កំណត់ហេតុនោះឱ្យទៅអ្នកដែលចូលរួមមើល ដោយខ្លួនឯងតែបើជនត្រូវចោទមិនចេះអក្សរទេ ត្រូវមានកំណត់ហេតុនោះឱ្យជនត្រូវចោទស្តាប់ ដោយសម្លេងខ្លាំងៗ បន្ទាប់មកត្រូវឱ្យអ្នកទាំងនោះចុះហត្ថលេខា ឬ ផ្តិតម្រាមដៃលើរឹមទំព័រគ្រប់សន្លឹកទាំងអស់នៃកំណត់ហេតុ។

- កំណត់ហេតុសួរចម្លើយជនត្រូវចោទ

បន្ទាប់ពីប្រាប់ពីសិទ្ធិពិនិត្យអត្តសញ្ញាណ និងប្រាប់អំពីសិទ្ធិរបស់ជនត្រូវចោទដល់ជនជាប់ចោទហើយធ្វើការកោះហៅមេធាវី ឬអ្នកជំនាញ (ប្រសិនបើមាន) ត្រឹមត្រូវតាមច្បាប់ហើយចៅក្រមស៊ើបសួរត្រូវធ្វើការសួរចម្លើយជនត្រូវចោទនៅចំពោះមុខ ដោយអមដោយក្រឡាបញ្ជី។ តែ

[៤០] មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៤១] ឧបសម្ព័ន្ធទី ១១

ជាពិតមានករណីមួយចំនួនការសួរចម្លើយជនត្រូវចោទ គឺធ្វើឡើងដោយក្រឡាបញ្ជី។ នៅក្នុងពេលសួរចម្លើយជនត្រូវចោទក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុសួរចម្លើយហើយនៅក្នុងកំណត់ហេតុក្រឡាបញ្ជីត្រូវកត់ឱ្យបានច្បាស់លា លាស់អំពីការសួរ និងឆ្លើយ។ បន្ទាប់ពីនោះក្រឡាបញ្ជីត្រូវត្រៀមៈ

➢ បំពេញរូបមន្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ[៤២]

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព ប៉ុន្តែជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន ដោយចៅក្រមស៊ើបសួរក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ០១ឆ្នាំ។[៤៣]នៅពេលដែលចៅក្រមស៊ើបសួរសម្រេចថា នឹងឃុំខ្លួនបណ្ដោះអាសន្ន ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទ។ នៅក្នុងដីកាឃុំខ្លួនបណ្ដោះអាសន្នត្រូវមានសំអាងហេតុដែលជាមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ហើយក្រោយចេញដីកាសម្រេចនេះ ក្រឡាបញ្ជី មានភារកិច្ចជាអ្នកជូនដំណឹងភ្លាមៗដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

➢ បំពេញរូបមន្តដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤៤]

នៅពេលជនត្រូវចោទបង្ហាញខ្លួនលើកដំបូង ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទទេ នោះចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីនេះក្រឡាបញ្ជីមានភារកិច្ចដូចតទៅៈ

- ✓ ធ្វើកំណត់ហេតុស្តីពីការចូរបង្ហាញខ្លួនជាលើកដំបូង
- ✓ ធ្វើសេចក្តីព្រាងដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ
- ✓ ធ្វើសេចក្តីព្រាងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

[៤២] ឧបសម្ព័ន្ធទី ១២
[៤៣] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៤៤] ឧបសម្ព័ន្ធទី ១៣

✓ សរសេរបង្កាន់ដៃប្រគល់ទទួលឯកសារបញ្ជាក់ អំពីអត្តសញ្ញាណជនត្រូវចោទ និង ចុះហត្ថលេខាដោយខ្លួនឯង។

✓ សរសេរបង្កាន់ដៃប្រគល់ប្រាក់ធានា ឬ អាវុធ ដាក់ជូនប្រធានតុលាការ ព្រះរាជអាជ្ញា ចុះហត្ថលេខា និងចុះហត្ថលេខាខ្លួនឯង។

✓ ជូនដំណឹងអំពីដីកាសម្រេចដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវ តុលាការដល់ព្រះរាជអាជ្ញា និងជនត្រូវចោទភ្លាម។ ចតចម្លងដីកាខាងលើនេះផ្ញើជូន ទៅអាជ្ញាធរណាដែលចៅក្រមស៊ើបសួរបង្គាប់ឱ្យអនុវត្តនូវដីកានោះ។

➢ សរសេរកំណត់ហេតុសួរចម្លើយជនត្រូវចោទ[៩៥]

ការសួរចម្លើយជនត្រូវចោទ គឺត្រូវធ្វើនៅចំពោះមុខចៅក្រមស៊ើបសួរដោយមេធាវីអម ប្រសិនបើជនត្រូវចោទមានមេធាវី ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីយ៉ាង តិចបំផុត ០៥ ថ្ងៃមុនការសួរចម្លើយ។ តែបើមេធាវីដែលបានកោះហៅត្រឹមត្រូវហើយ មិនចូលមក បង្ហាញខ្លួនតាមថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មាន វត្តមានមេធាវីបាន ហើយនិទ្ទេសស្តីពីការអវត្តមាននេះត្រូវចុះក្នុងកំណត់ហេតុសួរចម្លើយ។ បើក្នុង ករណីជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ឬករណីបន្ទាន់ចៅក្រម ស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវីក៏បាន។[៩៦]ជាក់ស្តែងនៅ សាលាដំបូងខេត្តកណ្តាល កាលសរសេរកំណត់ហេតុសួរចម្លើយត្រូវធ្វើដោយក្រឡាបញ្ជី ចំពោះ ករណីដូចខាងលើក្រឡាបញ្ជីចុះនិទ្ទេសនៅក្នុងកំណត់ហេតុសួរចម្លើយនោះតែម្តង ហើយបន្ទាប់ពី ការសួរចម្លើយត្រូវបានបញ្ចប់ក្រឡាបញ្ជីឱ្យជនត្រូវចោទអានដោយខ្លួនឯង លើកលែងតែករណី ដែលជនត្រូវចោទមិនចេះអានអក្សរ ទើបក្រឡាបញ្ជីត្រូវអានឱ្យស្តាប់។ បន្ទាប់ពីបញ្ចប់ការអាន កំណត់ហេតុ បើមានចំណុចណាដែលជនត្រូវចោទចង់កែប្រែ ឬបន្ថែម ក្រឡាបញ្ជីត្រូវធ្វើការកែប្រែ តាមការប្រាប់របស់ជនត្រូវចោទ តែបើមិនមានចំណុចចង់កែប្រែ ឬបន្ថែមទេ ក្រឡាបញ្ជីត្រូវឱ្យជន ត្រូវចោទផ្តិតម្រាមដៃនៅរឹមទំព័រ និងត្រូវសរសេរឈ្មោះនៅចំណុចកំណត់ហេតុ។

[៩៥] មាត្រា ឧបសម្ព័ន្ធទី ១៤

[៩៦] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ខ.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

រាល់ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី និងសួរចម្លើយដោយចៅក្រមស៊ើបសួរ ប៉ុន្តែបើដើមបណ្តឹងរដ្ឋប្បវេណីមិនមានមេធាវីទេ ការស្តាប់ចម្លើយធ្វើឡើងដោយក្រឡាបញ្ជី ហើយពេលខ្លះមិនមានវត្តមានរបស់ចៅក្រមស៊ើបសួរចូលរួមជាមួយទេ។ ក្នុងករណីខាងលើក្រឡាបញ្ជីត្រូវមានភារកិច្ចព្រាងនូវរូបមន្តដីកាមួយចំនួនដូចជា៖

- ✓ រូបមន្តដីកាសម្រេចទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- ✓ ព្រាងលិខិតជូនដំណឹង
- ✓ បំពេញរូបមន្តដីកាកោះហៅមេធាវី ឬអ្នកបកប្រែភាសា
- ✓ បំពេញរូបមន្តដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី
- ✓ សរសេរកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

## កថាខណ្ឌទី៣ ភារកិច្ចក្រឡាបញ្ជីក្នុងកិច្ចបិទការស៊ើបសួរ

នៅពេលដែលការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោះស្រាយ ដូចនេះក្រឡាបញ្ជីត្រូវជូនពត៌មានទៅព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ពីរថ្ងៃក្រោយត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ រយៈពេល ១៥ថ្ងៃបើជនត្រូវចោទឃុំខ្លួន និង ១ខែក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។[៩៧] ក្នុងករណីខាងលើនេះក្រឡាបញ្ជីមានភារកិច្ចមួយចំនួនដូចខាងក្រោម៖

### ៣.១.ករណីជនត្រូវចោទនៅក្រៅឃុំ

នៅក្នុងករណីនេះក្រឡាបញ្ជីត្រូវព្រាងដីកាដូចខាងក្រោម៖

- ✓ ព្រាងលិខិតជូនពត៌មានទៅព្រះរាជអាជ្ញា[៩៨]
- ✓ ព្រាងលិខិតជូនពត៌មានទៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី
- ✓ ព្រាងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ

[៩៧] មាត្រា ២៤២ នៃក្រមនីតិវិធីប្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៨] ឧបសម្ព័ន្ធទី ១៥

**៣.២.ករណីជនត្រូវចោទនៅក្នុងឃុំ**

- ✓ ព្រាងលិខិតជូនពត៌មាន
- ✓ ព្រាងលិខិតជូនពត៌មានទៅជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី
- ✓ ព្រាងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ឧទារហណ៍ឧបសម្ព័ន្ធទី១៦
- ✓ ព្រាងដីកាបង្គាប់ដោះលែងជនត្រូវចោទ ឬព្រាងដីកាបង្គាប់ឱ្យរក្សាជនត្រូវចោទ

**៣.៣.តួនាទីក្នុងការគ្រប់គ្រងថែរក្សាសំណុំរឿងក្រោយការស៊ើបសួរ**

សំណុំរឿងស៊ើបសួរត្រូវរក្សាទុកនៅការិយាល័យក្រឡាបញ្ជី។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន។[៥៩] លិខិតចម្លងនេះត្រូវបញ្ជាក់ថា ត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី។ គ្រប់លិខិត នៃសំណុំរឿងត្រូវបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។ សំណុំរឿងនិងសំណុំលិខិត ដែលបង្កាទុកត្រូវរក្សានៅការិយាល័យក្រឡាបញ្ជីនៅមន្ទីស៊ើបសួរ ឬ នៅក្នុងបន្ទប់ណាមួយនៃសវនាការដែលមានសន្តិសុខគ្រប់គ្រាន់។ មេធាវី ឬលេខារបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យធ្វើការថតចម្លងសំណុំរឿងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។

**.៣.៤.តួនាទីក្នុងការទទួលបណ្ដឹងឧទ្ធរណ៍**(ប្ដឹងទៅសភាស៊ើបសួរ)

សាលាឧទ្ធរណ៍គ្រប់ដណ្ដប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ភាគីដែលមិនសុខចិត្តទៅនឹងសេចក្ដីសម្រេចសាលាដំបូងអាចប្ដឹងទៅតុលាការជាន់ខ្ពស់ដែលមានឈ្មោះថា សាលាឧទ្ធរណ៍ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។

ក្រឡាបញ្ជីមានមុខងារចុះបណ្ដឹងឧទ្ធរណ៍ ទៅក្នុងសៀវភៅទទួលបណ្ដឹងនៃសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីរៀបចំសំណុំរឿងបង្កាទុកបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដោយមានឯកសារគ្រប់ទាំងអស់ ដែលទាក់ទងនឹងរឿងក្ដីពិសេសត្រូវចុះលេខគ្រប់ឯកសារនៃសំណុំរឿង។ ក្រឡាបញ្ជីធ្វើបញ្ជីរាយនាមលិខិតដែលមាននៅក្នុងក្របសំណុំរឿង និងសេចក្ដីព្រាងលិខិត បញ្ជូនជូនទៅសភាស៊ើបសួរ។ ក្រឡាបញ្ជីត្រូវរក្សាទុកសំណុំរឿងដើមបញ្ជូនទៅចៅក្រមស៊ើបសួរចាត់ការបន្ត លើកលែងតែសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍សម្រេចថា ដកសំណុំរឿងប្រគល់ទៅចៅក្រមស៊ើបសួរផ្សេង ឬសភាស៊ើបសួរខ្លួនឯងចាត់ការបន្ត។ ក្រឡាបញ្ជីជាអ្នកបញ្ជូនសំណុំរឿងបង្កាទុកទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរក្នុងរយៈ

[៥៩] មាត្រា ១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ពេល ៥ថ្ងៃ បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈពិសេស ដែលមិនអាចជម្រះបាន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាអាជ្ញាអមសាលាដំបូងរាជធានី/ខេត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍ គ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។[៥០] ប្រភេទដីកា ដែលអាចជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ មានដូចជា ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសល្យវិច័យ ដីកាមិនព្រមប្រគល់វត្ថុតាងដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដីកាព្រមប្រគល់វត្ថុតាងដែលចាប់យកប្រគល់ឱ្យម្ចាស់ដើមវិញ ដីកាបដិសេធពាក្យសុំអ្វើកោសល្យវិច័យ ដីកាស្ដីពីរឿងឃុំខ្លួនបណ្ដោះអាសន្ន ដីកាត្រួតពិនិត្យតាមផ្លូវតុលាការ ដីកាដោះស្រាយទាក់ទងនឹងការឃុំខ្លួនបន្ត ដីកាមិនព្រមស៊ើបសួរ ដីកាកំណត់ចំនួនទឹកប្រាក់កក់ ដីកាប្រកាសមិនទទួលពាក្យបណ្ដឹងដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដីកាផ្ដន្ទាទោសដើមបណ្ដឹងរដ្ឋប្បវេណី ដីកាបដិសេធពាក្យសុំធ្វើកោសសល្យវិច័យ ដីកាបដិសេធពាក្យសុំធ្វើកោសល្យវិច័យបន្ថែម ឬ ពាក្យសុំឱ្យធ្វើប្រត្តិកោសល្យវិច័យ ដីកាដំណោះស្រាយ។

## ជំពូកទី ៣ ដំណាក់កាលជំនុំជម្រះ

នៅតាមបណ្ដាខេត្ត និងរាជធានីមានសាលជម្រះក្ដីមួយដែលមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីរាជធានី/ខេត្តទាំងមូលហៅថា សាលាដំបូង។[៥១]ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម នឹងបទលហុ។ សាលាដំបូងជំនុំជម្រះជាក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ៣(បី)រូប ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលជាប់ទាក់ទង ប៉ុន្តែសាលាដំបូងសម្រេចជាចៅក្រមទោល ចំពោះបទមជ្ឈិម និងបទលហុ។[៥២]

### ផ្នែកទី១ តួនាទីក្រឡាបញ្ជីមុនពេលសវនាការ

ការរៀបចំសវនាការ គឺជានីតិវិធីមួយនៅក្នុងវិស័យតុលាការហើយការរៀបចំនេះគឺដើម្បីធ្វើការកោះហៅគ្រប់ភាគីដែលពាក់ព័ន្ធឱ្យបានដឹង និងដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿង។ ការរៀបចំសនវការក៏ជាការចាត់តាំងឱ្យចៅក្រមអាសនៈទទួលយកសំណុំរឿង ដើម្បីធ្វើចំណាត់ការ

[៥០] ជ័យ សុផល ឯកសារបង្រៀននៅសាលាភូមិន្ទក្រឡាបញ្ជី ឆ្នាំ២០០៩ ស្ដីពីមុខងារក្រឡាបញ្ជីក្នុងការស៊ើបសួរ

[៥១] មាត្រា ២៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥២] មាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បន្ត។ក្នុងន័យនេះការរៀបចំសវនាការមានគោលដៅឱ្យយុត្តាធិការជំនុំជម្រះធ្វើការវិនិច្ឆ័យលើសំណុំដូច្នេះតួនាទីជាការងារក្រឡាបញ្ជី។

### កថាខណ្ឌទី១ តួនាទីនាក់តែងលិខិតផ្សេងៗ

#### ១.១.ពិនិត្យការបរិច្ឆេទនៃជំនុំជម្រះ

ការបរិច្ឆេទនៃសវនាការលើសំណុំរឿងក្តីព្រហ្មទណ្ឌទាំងអស់ត្រូវកំណត់ដោយប្រធានតុលាការ។ ជាទូទៅប្រធានតុលាការបែងចែកតារាងចៅក្រមទទួលបន្ទុកជំនុំជម្រះទៅតាមចៅក្រមនីមួយៗ សម្រាប់រយៈពេល១ឆ្នាំ។

នៅពេលដែលក្រឡាបញ្ជីទទួលបានសំណុំរឿងពីការចាត់តាំងរបស់ចៅក្រមជំនុំជម្រះរួចហើយក្រឡាបញ្ជីត្រូវពិនិត្យមើលកាលវិភាគដែលប្រធានតុលាការបានកំនត់តាមរយៈដីកាសម្រេចប្រចាំឆ្នាំ ហើយជំរាបប្រាប់ចៅក្រមពីថ្ងៃដែលជំនុំជម្រះដោយគោរពទៅតាមវេនវេលា ដូចមានចែងក្នុង ៤៥៧ និងមាត្រា ៤៦៦នៃក្រមនីតិវិធីដែលកំនត់កាលបរិច្ឆេទបើកសវនាការ (មាត្រា ២៩២នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។តាមពិតការកំណត់ថ្ងៃ សវនាការជាក់លាក់ គឺជាការសម្រេចរបស់ចៅក្រមជំនុំជម្រះនីមួយៗដោយអាស្រ័យទៅលើការកោះហៅជនជាប់ចោទមកកាន់តុលាការ។ ចំពោះការកំណត់ថ្ងៃជាសិទ្ធិអំណាចរបស់ប្រធានតុលាការ គឺអាស្រ័យលើសាលសវនាការ ព្រោះមានចំនួនតិចហើយការធ្វើបែបនេះ គឺដើម្បីបញ្ចៀសកុំឱ្យមានភាពជួនថ្ងៃគ្នានៃជំនុំជម្រះរបស់ចៅក្រម។

#### ១.២.នាក់តែងរូបមន្តដីកាចាត់តំណាងអយ្យការ

ជាទូទៅការជម្រះរឿងក្តីព្រហ្មទណ្ឌតម្រូវឱ្យមានតំណាងអយ្យការម្នាក់ ជាដើមបណ្តឹងអាជ្ញាដែលជាអ្នកការពារផលប្រយោជន៍ដល់សង្គម និងភាគីដើមបណ្តឹង។ ព្រះរាជអាជ្ញាចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ឬចាត់តាំងខ្លួនឯងតាមដែលខ្លួនយល់ឃើញថាសមរម្យ។[៤៦]ជាធម្មតាមុនពេលចាប់ផ្តើមដំណើរការស៊ើបអង្កេតបឋមតំណាងអយ្យការត្រូវបានចាត់តាំងឱ្យទទួលបន្ទុកសំណុំរឿងនោះរួចហើយ ដូចនេះពេលជំនុំជម្រះបើគ្មានការផ្លាស់ប្តូរតំណាងអយ្យការទេនោះគេមិនចាំបាច់ធ្វើការចាត់តាំងតំណាងអយ្យការថ្មីទៀតទេ។

[៤៦] យោបលតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ (អតីតព្រះរាជអាជ្ញារង ខេត្តបាត់ដំបង)

**១.៣.រៀបសំណុំរឿងមុនជំនុំជម្រះ**

សំណុំរឿងជាទូទៅមិនមានលំដាប់តាមលេខរៀងត្រឹមត្រូវនោះទេ ព្រោះការបញ្ចូលឯកសារមុនក្រោយ ដូចជា របាយការណ៍របស់សមត្ថកិច្ច ដីកាផ្សេងៗ ពាក្យពឹងពាក់មេធាវី....។ ដូច្នេះក្រឡាបញ្ជីត្រូវរៀបទៅតាមលំដាប់នៃលេខរៀង ឬដកយកឯកសារសំខាន់ៗដែលចាំបាច់ដូចជាភស្តុតាង(ដែលភាគីដាក់បញ្ចូលក្នុងរឿងបើមាន) របាយការណ៍សំយោគពីសមត្ថកិច្ចកំណត់ហេតុ(ចម្លើយរបស់ជនជាប់ចោទគ្រប់ដំណាក់កាល) ដើម្បីឱ្យមានភាពងាយស្រួលថៅក្រមជំនុំជម្រះយកមើល និងងាយស្រួលសួរដេញដោលជនល្មើសពេលជំនុំជម្រះក្នុងសវនាការ។[៩៧]

**១.៤.កោះហៅភាគីពាក់ព័ន្ធ**

ក្រឡាបញ្ជីត្រូវតាក់តែងដីកាបង្គាប់ឱ្យជនជាប់ចោទមកតុលាការតាមពេលកំណត់ដោយជូនដំណឹងទៅអគ្គពន្ធនាគារនីមួយៗនៃបណ្តាលរាជធានី/ខេត្តនីមួយៗដែលឃុំជនជាប់ចោទ។ ប្រធានពន្ធធនាគារនឹងចុះហត្ថលេខាទទួលរួច ផ្ញើរត្រឡប់មកវិញ ដើម្បីក្រឡាបញ្ជីរក្សាទុកក្នុងសំណុំរឿង។

ក្រឡាបញ្ជីត្រូវតាក់តែងដីកាកោះភាគីផ្សេងៗទៀតដូចជា ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ មេធាវី ឬចាត់តាំងមេធាវី។ ដោយក្នុងនោះមានបញ្ជាក់ពីឈ្មោះជនជាប់ចោទ ថ្ងៃ ខែ ឆ្នាំ បន្ទប់ជំនុំជម្រះជាដើម។

**១.៥.រៀបចំបន្ទប់សវនាការ**

នៅតាមសាលាដំបូងនីមួយៗតែងតែមានបន្ទប់សវនាការ១ ឬ២ស្ថិតទៅលើតាមបណ្តាលខេត្តនីមួយៗ។ ជូនកាលការរៀបចំបន្ទប់ទុកដាក់ រៀបចំកន្លែងអង្គុយទាំងសាក្សី ជនជាប់ចោទ និងសាធារណៈជននោះជាមន្ត្រីទទួលបន្ទុកផ្សេង ប៉ុន្តែខេត្តមួយចំនួនប្រគល់តួនាទីនោះឱ្យទៅក្រឡាបញ្ជី។

ដូច្នេះក្រឡាបញ្ជីមុនពេលបើកសវនាការ ក្រឡាបញ្ជីត្រូវរៀបចំឱ្យមានរបៀបរៀបរយល្អទៅតាមបទបញ្ជាផ្ទៃក្នុង ដោយក្រឡាបញ្ជីត្រូវរៀបចំ តុក្រចកសេះ សម្រាប់ជនជាប់ចោទឈរកន្លែងអង្គុយរងចាំសាក្សី។ ចំពោះសាក្សីវិញនៅពេលចូលសវនាការក្រឡាបញ្ជីត្រូវធ្វើការរៀបចំកន្លែងសម្រាប់សាក្សីអង្គុយនៅក្នុងបន្ទប់របស់សាក្សី ដោយមិនអនុញ្ញាតឱ្យសាក្សី អង្គុយស្តាប់ក្នុងអំឡុងពេលសវនាការដែលកំពុងតែសួរចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះឡើយ។

[៩៧] ការអនុវត្តផ្ទាល់នៅសាលាដំបូងរាជធានីភ្នំពេញ

ប្រសិនបើរឿងក្តីខ្លះជាបទល្មើសសាហាវ ឬបទល្មើសជាអសាធារណៈ(ឃាតកម្មឃោរឃៅ រំលោភសេពសន្ថវៈ ឬបទល្មើសផ្សេងៗ...) នោះក្រឡាបញ្ជីត្រូវរៀបចំរាំងននសម្រាប់ជនរងគ្រោះជាអនីតិជន ឬអញ្ជើញសាធារណៈជនដែលមិនមែនជាភាគីពាក់ព័ន្ធអង្គុយនៅបន្ទប់រងចាំ។

## ផ្នែកទី២ តួនាទីក្រឡាបញ្ជីក្នុងពេលសវនាការ

### កថាខណ្ឌទី១ ប្រកាសបើកសវនាការ

-ក្រឡាបញ្ជីអញ្ជើញគូភាគីដែលពាក់ព័ន្ធក្នុងនីតិវិធីទាំងអស់មកក្នុងបន្ទបសវនាការ

-អានបទបញ្ជាផ្ទៃក្នុងពេលសវនាការ

-ស្ទួរកណ្តឹង ៣ដងគឺជាសញ្ញាប្រាប់អំពីការចូលបន្ទប់សវនាការនៃប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-ក្រឡាបញ្ជីអញ្ជើញសាធារណៈជនក្រោកឈរពេលដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ និងតំណាងអយ្យការ ចូលមកក្នុងសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមជំនុំជម្រះ និងតំណាងអយ្យការចូលទៅអង្គុយលើអាសនៈ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ អញ្ជើញក្រុមប្រឹក្សាជំនុំជម្រះ តំណាងអយ្យការក្រឡាបញ្ជី មេធាវី និងគូភាគី អង្គុយចុះតាមទីកន្លែងដែលបានរៀបចំទុក

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ បង្គាប់ឱ្យក្រឡាបញ្ជីរាយការណ៍អំពីវត្តមាន និងអវត្តមានរបស់គូភាគីដែល ពាក់ព័ន្ធនៅក្នុងនីតិវិធី

-ក្រឡាបញ្ជីក្រោកឈរធ្វើការរាយការណ៍អំពីវត្តមានរបស់ភាគីដែលពាក់ព័ន្ធ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ ក្រោកឈរប្រកាសអំពីសមាសភាពរបស់តុលាការ ហើយសួរអំពីអត្តសញ្ញាណ (នាមត្រកូល ឈ្មោះ អាយុ សញ្ជាតិ លំនៅដ្ឋានបច្ចុប្បន្ន របររកស៊ី ឈ្មោះប្តី ឬប្រពន្ធ រួចប្រាប់ពីសិទ្ធិ កាតព្វកិច្ចរបស់គូភាគី)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះប្រាប់ដល់ជនជាប់ចោទឱ្យបានដំណឹងអំពីអំពើដែលគេបានចោទប្រកាន់ នឹងធ្វើការសួរចម្លើយជនជាប់ចោទនោះ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះប្រាប់ពីសិទ្ធិ និងកាតព្វកិច្ចដល់សាក្សី អ្នកជំនាញដែលបានធ្វើកោសល្យវិច័យ និងអ្នកបកប្រែ។

**កថាខណ្ឌទី២ ទម្រង់នៃកំណត់ហេតុសវនាការ**

ការកត់ត្រា គឺជាដំណើរការ និងការរៀបចំយ៉ាងជាក់លាក់របស់ក្រឡាបញ្ជី ក្នុងការសសេរដោយផ្ទាល់ ឬថតចម្លងដោយឧបករណ៍អេឡិចត្រូនិច ទៅលើដំណើរការនៃការប្រព្រឹត្តទៅក្នុងការរុករកនូវរបកគហើញនានា ចំពោះអង្គហេតុនៃរឿងក្ដីរបស់តុលាការ តាមរយៈនៃសាកសួរ ហើយដំណើរការនឹងការប្រព្រឹត្តទៅទាំងនោះត្រូវបានកំណត់យ៉ាងជាក់លាក់ដោយច្បាប់នីតិវិធី។[៥៨]

ទម្រង់នៃកំណត់ហេតុចែកចេញជា ៤ ផ្នែកគឺះ

-លេខ ថ្ងៃ ខែ ឆ្នាំ នៃសំណុំរឿង

-លេខ ថ្ងៃ ខែ ឆ្នាំ សាលក្រម

-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងបើកសវនាការ

-ឈ្មោះ និងតួនាទីក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ

-ឈ្មោះ តួនាទីតំណាងអយ្យការ

-ឈ្មោះ ក្រឡាបញ្ជី

-ឈ្មោះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

-សាវតាជាតិ ជនជាប់ចោទ បទល្មើស ទីកន្លែង និងពេលវេលាប្រព្រឹត្តបទល្មើស មាត្រាច្បាប់ដែលបានចោទប្រកាន់។

-អត្តសញ្ញាណ និងលំនៅដ្ឋានអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

- **ផ្នែកសំនួរចម្លើយ និងសេចក្ដីសន្និដ្ឋាននានា**

កត់ត្រានូវព្រឹត្តការណ៍ទាំងអស់តាមលំដាប់លំដោយនៃនីតិវិធីសួរដេញដោលរួមមានដូចខាងក្រោមះ

សំនួរ-ចម្លើយ ជនជាប់ចោទ

- សំនួរ-ចម្លើយ ដើមបណ្ដឹងរដ្ឋប្បវេណី
- សំនួរ-ចម្លើយ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- សំនួរ-ចម្លើយ ជនរងគ្រោះ
- សំនួរ-ចម្លើយ សាក្សីដាក់បន្ទុក
- សំនួរ-ចម្លើយ សាក្សីដោះបន្ទុក

- សំនួរ-ចម្លើយ សាក្សីបំភ្លឺ
- សំនួរ-ចម្លើយ សួរតទល់
- សំនួរ-ចម្លើយ សួរតទល់
- សេចក្តីសន្និដ្ឋាន របស់អ្នកជំនាញ
- សំដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល
  - ➢ ដើមបណ្តឹងរដ្ឋប្បវេណី
  - ➢ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
  - ➢ ជនជាប់ចោទ
- សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី
- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- សេចក្តីសន្និដ្ឋានតទល់

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះសួរខុសពីលំដាប់ខាងលើនេះក្រឡាបញ្ជីត្រូវកត់ត្រាទៅតាមការសួរមុន សួរបន្ទាប់ និងសួរក្រោយ។

ប្រសិនបើជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬសាក្សីច្រើននាក់ ក្រឡាបញ្ជីត្រូវកត់ត្រាតាមលំដាប់នៃការសួរមុន សួរបន្ទាប់ និងសួរក្រោយ។

**កថាខណ្ឌទី៣ ការថយទៅពិភាក្សា**

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាជាមួយក្រុមប្រឹក្សាជំនុំជម្រះដើម្បីសម្រេច។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិក្សាសម្រេចនេះទេ ហើយគ្មានបណ្តឹងសុំណាមួយអាចត្រូវបានដាក់ ជូនដល់តុលាការបានទៀតទេ។ គ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ។ ក្រោយពីកិច្ចពិក្សាដេញដោលរួចសាលក្រមអាចនឹងត្រូវធ្វើការប្រកាសភ្លាម ប៉ុន្តែប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចមានសិទ្ធិក្នុងការលើកទៅប្រកាសនៅកាលបរិច្ឆេទលើកក្រោយ ក្នុងករណីនោះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសឱ្យអ្នកចូលរួមទាំងអស់ បានដឹង អំពីកាលបរិច្ឆេទ ម៉ោង ប្រកាស និងបន្ទប់សាលសវនាការដែលត្រូវប្រកាសសាលក្រមនោះ។

[៥៨] អ៊ិន បូផា បច្ចេកទេសក្នុងការកត់ត្រាកំនត់ហេតុ ២០១៤

**កថាខណ្ឌទី៤ សុពលភាពនៃកំណត់ហេតុជំនុំជម្រះ**

នៅពេលសវនាការក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដែលមានគោលដៅផ្ដល់មធ្យោបាយដល់សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល។ ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពី ការប្រព្រឹត្តទៅសវនាការ និងការកត់ត្រាឱ្យបានត្រឹមត្រូវតាមសំនួរដែលសួរ ព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ។ កំណត់ហេតុសវនាការ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការបកក្រោយពីការផ្ទៀងផ្ទាត់ ដោយប្រធានសវនាការក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយពីថ្ងៃប្រកាសសាលក្រម។

សុពលភាពនៃកំណត់ហេតុសវនាការ ពិតជាមានសារៈសំខាន់ណាស់ដែលតម្រូវឱ្យក្រឡាបញ្ជីមានភារកិច្ចក្នុងការតាក់តែងកំណត់ហេតុសវនាការនោះឱ្យមានសុពលភាព។

សុពលភាពនៃកំណត់ហេតុ ក្រឡាបញ្ជីត្រូវតាក់តែងមានលក្ខណៈដូចខាងក្រោម៖

-សរសេរឱ្យបានត្រឹមត្រូវតាមទម្រង់

-សរសេរឱ្យបានផ្ចិតផ្ចង់ តួអក្សរច្បាស់លាស់ត្រឹមត្រូវតាមអក្ខរាវិរុទ្ធ

-មិនត្រូវកោសលុបបើករណីកោសលុបត្រូវឆូតចំពាក់កណ្ដាលនៃតួអក្សរឱ្យនៅមើលឃើញតួអក្សរដែលបានកោសលុប ហើយក្រឡាបញ្ជីត្រូវចុះនិទ្ទេស និងចុះហត្ថលេខានៅរឹមទំព័រដែលបានកោសលុបនោះ។

-ការសរសេរកំណត់ហេតុត្រូវសរសេរដោយទឹកប៊ិចតែមួយ ជៀសវៀងការសរសេរទឹកប៊ិចពីរពណ៌។

-កំណត់ហេតុត្រូវសរសេរជាអក្សរ លើកលែងតែលេខផ្ទះ លេខយានយន្ត លេខឯកសារដើមទើបត្រូវសរសេរជាលេខ ប៉ុន្តែបើជាចំនួនដូចជា ចំនួនទឹកប្រាក់ ត្រូវសរសេរជាលេខ និងសរសេរជាអក្សរបន្ថែមដោយដាក់នៅក្នុងរង្វង់ក្រចក។

-ចម្លើយរបស់ភាគី និងសាក្សី ដែលបានឆ្លើយព្រមទាំងសេចក្ដីសន្និដ្ឋាននានា របស់អ្នកជំនាញ តំណាងអយ្យការ និងមេធាវី ក្រឡាបញ្ជីត្រូវកត់ត្រាចូលក្នុងកំណត់ហេតុសវនាការនោះដោយមិនត្រូវបន្ថែមឬបន្ថយខ្លឹមសារ ប៉ុន្តែក្រឡាបញ្ជីត្រូវចេះកត់ត្រាគួបផ្សំខ្លឹមសារសរសេរឱ្យខ្លីងាយស្ដាប់ងាយយល់ ប៉ុន្តែអត្ថន័យនៅដដែល។

តុលាការអាចប្រកាសថា មិនអាចទទួលបាននូវបញ្ញាបន្ទាន់បង្ខំតែតាមសាលក្រម ដែលមានសំអាងហេតុប៉ុណ្ណោះ។ កាលណាអញ្ញត្រកម្មមិនបានទទួលការយល់ព្រមទេ ការពិភាក្សាដេញ

ដោលត្រូវបន្ត។ កាលណាបញ្ហាបន្ទាន់បង្ខំត្រូវបានលើកឡើង និងត្រូវបានទទួលយល់ព្រមដោយតុលាការនោះ តុលាការត្រូវបង្អង់មិនទាន់សម្រេច ហើយកំណត់រយៈពេលឱ្យភាគីពាក់ព័ន្ធប្ដឹងទៅតុលាការមានសមត្ថកិច្ច លុះផុតរយៈពេល ប្រសិនបើភាគីពាក់ព័ន្ធបង្ហាញភស្តុតាងថា បានប្ដឹងតុលាការមានសមត្ថកិច្ចហើយ តុលាការកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឱ្យសេចក្ដីសម្រេចអំពីបញ្ហានេះ។ តុលាការត្រូវតែទទួលបណ្ដឹងត្រូវបានទទួលដំណឹងពីរយៈពេលនេះពីព្រះរាជអាជ្ញា។

បើគ្មានសេចក្ដីសម្រេចនៅក្នុងរយៈពេលដែលបានកំណត់ ដោយតុលាការនោះទេរឿងព្រហ្មទណ្ឌចាប់ដំណើរការតទៅមុខទៀត ប្រសិនបើមានការយឺតយ៉ាវនោះ ជាកំហុសបណ្ដាលមកពីការធ្វេសប្រហែសរបស់ភាគីពាក់ព័ន្ធ។

## ផ្នែកទី៣ តួនាទីក្រឡាបញ្ជីក្នុងការប្រកាសសាលក្រម

### កថាខណ្ឌទី១ កិច្ចការក្រឡាបញ្ជីក្នុងពេលប្រកាសសាលក្រម

- ពេលស្នូរកណ្ដឹង ៣ដង ក្រឡាបញ្ជីអញ្ជើញគូភាគី និងអ្នកពាក់ព័ន្ធនៅក្នុងបន្ទប់សវនាការ
- ស្នូរកណ្ដឹង ៣ដងជាសញ្ញាប្រាប់អំពីការចូលបន្ទប់សវនាការនៃក្រុមប្រឹក្សាជំនុំជម្រះ
- ក្រឡាបញ្ជីអញ្ជើញភាគីដែលមានវត្តមាននៅក្នុងបន្ទប់សវនាការក្រោកឈរ
- ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ ចូលទៅកាន់អសនៈ ប្រធានសវនាការប្រាប់ទៅសាធារណៈជនឱ្យអង្គុយចុះ
- ប្រធានក្រុមប្រឹក្សាក្រោកឈរប្រកាសបើកការជំនុំជម្រះ ប្រកាសកម្មវត្ថុនៃរឿងហេតុ និងឈ្មោះគូភាគី
- ប្រធានបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការរាយការណ៍អំពីវត្តមាន របស់គូភាគី និងអវត្តមានអ្នកដែលត្រូវចូលរួមក្នុងនីតិវិធី។
- ក្រឡាបញ្ជីត្រូវក្រោកឈរហើយរាយការណ៍ បើមានអ្នកចូលរួមណាមានវត្តមាន ឬបើមានសំណូមពរពីភាគីណាស្នើរឱ្យផ្អាកសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពិចារណា ថាត្រូវបន្តសវនាការ ឬបង្អង់សវនាការដើម្បីបន្តទៅថ្ងៃក្រោយ។
- ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្រោកឈរប្រកាសសមាសភាពរបស់តុលាការ ហើយសួរអត្តញ្ញាណរបស់គូភាគី រួចប្រាប់ពីសិទ្ធិ និងកាតព្វកិច្ចដល់គូភាគី

- ការពិភាក្សាសួរដេញដោលរួច ប្រធានក្រុមប្រឹក្សាអាចថយទៅពិភាក្សាដេញដោល នៅក្នុងបន្ទប់សម្ងាត់ ដែលទាក់ទងទៅ និងអង្គហេតុ អង្គច្បាប់ សិទ្ធិនិងកាតព្វកិច្ច របស់គូភាគី។
- ក្រោយពិភាក្សាដេញដោយរួច ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រុមប្រឹក្សាជំនុំជម្រះ ត្រលប់មកបន្ទប់សវនាការវិញ ហើយប្រធានក្រុមប្រឹក្សាជំនុំជម្រះក្រោកឈរអាន សាលក្រម។ ហើយក្រឡាបញ្ជីត្រូវប្រាប់ទៅកាន់សាធារណៈជនឱ្យក្រោកឈរ។
- លុះការប្រកាសចប់ប្រធានក្រុមប្រឹក្សាប្រាប់ទៅកាន់សាធារណៈជនឱ្យអង្គុយចុះ។ ហើយក្នុងពេលប្រកាសសាលក្រមនោះ ក្រឡាបញ្ជីមានកិច្ចការកត់ត្រាកំណត់ហេតុ ស្តីពីការប្រកាសសាលក្រមដើម្បីរក្សាទុកនៅក្នុងសំណុំរឿង។ នៅឧបសម្ព័ន្ធទី (កំណត់ហេតុស្តីពីការប្រកាសសាលក្រម)

### កថាខណ្ឌទី២ ធ្វើលិខិតជូនដំណឹងសាលក្រមកំបាំងមុខ

ជាទូទៅនាពេលសវនាការ មិនប្រាកដថា គូភាគីពាក់ព័ន្ធទាំងអស់ចូលក្នុងសវនាការនោះទេ។ ចំពោះសេចក្តីសម្រេចដែលចេញដោយចៅក្រមជំនុំជម្រះ តែអវត្តមានភាគីណាមួយហៅថា សាលក្រមកំបាំងមុខ។ ក្រឡាបញ្ជីព្រាងលិខិតជូនដំណឹងដល់ភាគីអវត្តមាន ដែលហៅថា លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខ។ រយៈពេលសម្រាប់ធ្វើប្តឹងទាស់ត្រូវធ្វើគឺ ១៥ថ្ងៃផ្តើមគិតពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខនោះត្រូវបានប្រគល់ផ្ទាល់ដៃពិរុទ្ធជន។ ប្រសិនបើពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមនេះមិនបាច់ប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ។[៤៩]
ក្រឡាបញ្ជីនៃតុលាការជាអ្នកកាន់កាប់បញ្ជីបណ្តឹងទាស់។ គូភាគី និងមេធាវីអាចពិនិត្យបញ្ជីនេះបានដោយសេរី។[៥០]សាលក្រមដែលជំនុំជម្រះចំពោះមុខគូភាគីទាំងសងខាង ហៅថា សាលក្រមចំពោះមុខ។ សាលក្រមនេះពុំធ្វើលិខិតជូនដំណឹងនេះទេ។ សាលក្រមនេះមានន័យថា ជាសាលក្រមបញ្ចប់រឿងក្តីនៅសាលាជម្រះក្តីរាជធានី/ខេត្ត ហើយជាសេចក្តីសម្រេចបើកច្រកឱ្យគូភាគីមានសិទ្ធិតវ៉ាទៅសាលាឧទ្ធរណ៍។

---

[៤៩] មាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥០] មាត្រា ៣៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដីកាឱ្យដំណឹង គឺជាលិខិតដែលឱ្យអំពីសេចក្តីសម្រេចរបស់តុលាការសម្រាប់ជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ ដើម្បីឱ្យទទួលបានដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ។[៥១]របៀបផ្សេងៗទៀតនៃការជូនដំណឹងត្រូវធ្វើឡើងដោយក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធររដ្ឋបាល អាជ្ញាធពន្ធនាគារ មន្ត្រីនរគ បាលជាតិ ឬកងរាជអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យជូន ដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ត្រូវតែគោរពតាមបទបញ្ជារបស់ព្រះរាជអាជ្ញា។[៥២]

ក្នុងករណីកមានបណ្តឹងឧទ្ធរណ៍ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីត្រូវផ្ញើទៅក្នុងរយៈពេលដ៏ខ្លីបំផុតជូនដល់ការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវកំណត់ហេតុជំនុំជម្រះ សេចក្តីចម្លងនៃសាលក្រម និងសេចក្តីចម្លងលិខិតប្តឹងឧទ្ធរណ៍ បញ្ជីរាយនាមលិខិតសរសេរបន្ថែមក្របសំណុំរឿង ដីកាបញ្ជូន។ ក្រឡាបញ្ជីសាលាដំបូងត្រូវបានបញ្ចប់នៅពេលដែលសំណុំរឿងបានបញ្ជូនដល់ក្រឡាបញ្ជីសាលាឧទ្ធរណ៍។

[៥១] មាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្វែងយល់បន្ថែមតាមរយៈប្រធានបទស្ដីពី **តួនាទីក្រឡាបញ្ជីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត** នេះយើងយល់ច្បាស់ពីដំណើរការនីតិវិធីនៃរឿងក្ដី និងយល់ច្បាស់ ពីការងារចំបង និងការងារបន្ទាប់បន្សំរបស់ក្រឡាបញ្ជី។ ប្រធានបទនេះពិតជាមានសារៈសំខាន់សម្រាប់សិស្សនិស្សិតដែលទើបតែបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន ដែលមានបំណងត្រៀមប្រឡងប្រជែងចូលរៀនវិជ្ជាជីវៈមួយនេះ ឬអ្នកសិក្សាស្រាវជ្រាវផ្សេងៗទៀតព្រោះតែច្បាប់ និង ឯកសារផ្សេងៗ ដែលទាក់ទងនឹងវិជ្ជាជីវៈមួយនេះមិនទាន់មានគ្រប់គ្រាន់នៅឡើយ ។

ឆ្លងតាមរយៈការបកស្រាយប្រធានបទមួយនេះ បានឆ្លុះបញ្ចាំងឱ្យយើងឃើញពីប្រវត្តិនៃការកាត់ក្ដីនិងការកើតប្រព័ន្ធតុលាការដំបូងនៅកម្ពុជាដែលក្នុងនោះផងដែរ មានការបង្កើតជាដើមបណ្ដឹងអាជ្ញា និងជំនួយការផ្នែកនីតិវិធីផងនោះ ដើម្បីកាត់បន្ថយភាពស្មុគស្មាញទាំងឡាយនៃនីតិវិធីដំណើរការរឿងក្ដីពីដំណាក់កាលមុនជំនុំជម្រះ រហូតដល់ដំណាក់កាលជំនុំជម្រះចប់ជាស្ថាពរ ។ ដោយនៅតាមដំណាក់កាលនីមួយៗយើងសង្កេតឃើញថា ក្រឡាបញ្ជីជាជំនួយការយ៉ាងសំខាន់សម្រាប់ចៅក្រម ព្រះរាជអាជ្ញា ទាំងនីតិវិធី និងទាំងបច្ចេកទេស នៅគ្រប់ដំណាក់កាល ។ យើងសង្កេតឃើញថា ក្រឡាបញ្ជីជាតួអង្គម្នាក់ដែលមានភាពសកម្មនឹងការងារ មើងមត់ មត់ចត់ និងមានភាពទំនួលខុសត្រូវខ្ពស់នឹងការងារ ព្រោះឃើញថា ចាត់តាំងពីពេលទទួលសំណុំពីនគរបាលយុត្តិធម៌ គឺក្រឡាបញ្ជីអ្នកកោះហៅភាគី បញ្ជូនពត៌មានផ្សេងៗទៅភាគីនៃរឿងក្ដី តាក់តែងលិខិតផ្សេងៗ កត់ត្រា និងតាក់តែងសាលដីកាជាដើម ។ មួយវិញទៀតនោះ គឺតម្រូវឱ្យក្រឡាបញ្ជីចេះ ច្បាប់សារធាតុ នីតិវិធី និងបច្ចេកវិទ្យាជាដើម ។ តាមស្ថានភាពជាក់ស្តែងការកក់ស្ទះសំណុំរឿងជាច្រើននៅតាមសាលាដំបូងរាជធានី/ខេត្ត គឺដោយសារតែកខ្វះក្រឡាបញ្ជី ដូចជានៅតាមសាលាដំបូងខេត្តប៉ៃលិន រតនៈគីរី មណ្ឌលគីរី កោះកុងនោះ ក្រឡាបញ្ជីម្នាក់បំរើការងារចៅក្រមពីរនាក់ ជាដើម។

ដូច្នេះក្រឡាបញ្ជីជាជំនួយការយ៉ាងសំខាន់សម្រាប់ដំណើរការរឿងក្ដីព្រហ្មទណ្ឌ គឺប្រកាន់ភ្ជាប់នូវគោលការណ៍ មិនលំអៀង ក្រមសីលធម៌ កិរិយាមាយាទ.សច្ចាធម៌ និងភាពឆាប់រហ័ស ។

[៥២] មាត្រា ៤៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងជ្រើសយកប្រធានបទស្ដី **តួនាទីក្រឡាបញ្ជីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី/ខេត្ត** យើងសង្កេតឃើញថា នៅមានភាពជម្រោងជម្រោងជម្រះនៅឡើយដោយមិនទាន់បែងចែកការងារឱ្យច្បាស់លាស់ថា តើសិទ្ធិ និងកាតព្វកិច្ចរបស់ក្រឡាបញ្ជីមានអ្វីខ្លះ?យើងពិនិត្យឃើញថា ការបំពាន់សមត្ថកិច្ចពីសំណាក់ក្រឡាបញ្ជីចំពោះតុលាការ ដោយសារតែអវត្តមានច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី និងអវត្តមានក្រមសីលធម៌ក្រឡាបញ្ជី នាំឱ្យក្រឡាបញ្ជីពេលខ្លះបំពាន់មុខងាររបស់ព្រះរាជអាជ្ញា ឬមុខងារចៅក្រម។

ការអនុវត្តជាក់ស្ដែងយើងសង្កេតឃើញមានចំនុចជាច្រើនដែលផ្ទុយនឹងបញ្ញត្តិច្បាប់

-ការសាកសួរដោញដោលចំពោះមុខនៅដំណាក់កាលអយ្យការ ជួនកាលព្រះរាជអាជ្ញាដៅសំណួរសម្រាប់ក្រឡាបញ្ជីសាក់សួរជំនួស

-ការចុះហត្ថលេខាលើលិខិតផ្សេងៗពេលខ្លះបំពានលើមុខងារព្រះរាជអាជ្ញា

-ការចេញលិខិតផ្សេងៗមិនត្រឹមត្រូវតាមលក្ខខណ្ឌនៅឡើយ

-ការកត់ត្រាកំណត់ហេតុក្នុងពេលសវនាការ គឺមិនមានភាពច្បាស់លាស់នៅឡើយ

-ការតាក់តែងសាលក្រមនៅតាមសាលាដំបូងរាជធានី/ខេត្តនីមួយៗមានទម្រង់ខុសប្លែក ខ្វះចំណុចដែលឱ្យតុលាការជាន់ខ្ពស់ពិបាកពិនិត្យពិចារណា

-ការបញ្ជូនដីកាកោះ លិខិតអញ្ជើញមេធាវី និងបញ្ជូនសំណុំរឿងទៅតុលាការជាន់ខ្ពស់មានភាពយឺតយ៉ាវ

-ការគ្រប់គ្រងថែរក្សាសំណុំរឿងមានភាពខ្វះខ្វា